# កម្ពុជសុរិយា

ទស្សនាវដ្ដី ផ្សាយដំណឹងខាងសាសនា និងអក្សរសាស្ត្រ បោះពុម្ពផ្សាយ
អំពីពុទ្ធសាសនបណ្ឌិត្យ

---

បណ្ណាធិការ ផ្នែកអក្សរសាស្ត្រ: ហ្លួងនិពន្ធមន្ត្រី ញ៉ុក-ថែម, បណ្ឌិត នៅ
ពុទ្ធសាសនបណ្ឌិត្យ
បណ្ណាធិការ ផ្នែកដំណឹងសាសនា: ព្រះគ្រូសុវណ្ណញាណ ស្វរ-ហាយ
ក្រុមជំនុំព្រះត្រៃបិដក នៅពុទ្ធសាសនបណ្ឌិត្យ

---

## បញ្ជីរឿង

*ផ្នែកអក្សរសាស្ត្រ* — ទំព័រ

លោក ហេង-យ៉ាន់ — កំពូលស្នេហា (តមក) . . . . . . . . . ៤៤៩
លោក ធុយ-ប៊ុនស្វរ — ឯកសះហស្សរាត្រី ភាគទី ១២ . . . . . . . ៤៦៦
ហ្លួងនិពន្ធមន្ត្រី ញ៉ុក-ថែម — ព្រះរាជប្រវត្តិ ព្រះបាទសម្ដេចព្រះជ័យជេស្ឋា (ព្រះអង្គស្ងួរ) (តមក) . . . . . . . . ៤៨១

*ផ្នែកសាសនា*

ព្រះគ្រូសុវណ្ណញាណ ស្វរ-ហាយ — ប្រយោជន៍របស់ធម្មៈក្នុងពុទ្ធសាសនា . . . . ៤៩៣
លោក ស៊ុន-ហ៊ាន — ធម្មាធិប្បាយ "សោវចស្សតា" . . . . . . ៤៩៨

---

ឆ្នាំទី ១៨ — លេខ ៩ ខែសេបតេមប្រ៍ ១៩៤៦ — ដំឡៃផ្សាវៈ ១ ឆ្នាំ ៣៥ រៀល ។

# លោក ហេង-យ៉ាន់ រៀបរៀង (តមក)

## វគ្គទី ១០

## បិតុស្រី

"បង ចុះគាត់មួយដែលចំណាំតែមកលេងនោះ ដូចម្ដេចក៏បាត់មិនដែលឃើញមុខមាត់សោះ" ណុជនេត្រសួរអាចារ្យ ។

"មែនហើយប្អូន បងក៏មិនបានជាគិត ដោយប្អូនហួនហែងបិតុបងប្រេនពេក." ។

ណុជនេត្រក៏អៀនគេចមុខចេញ អាចារ្យក៏សួរជូនឡើងថា :

"ចុះប្អូនសាកសួររកវាមានការអ្វី?"

"ចាះទេ សួរចង់ដឹងទៅណា"

ពេលនោះអាចារ្យតិតឿនអ៊ូមួយឡើងទាន់ យកដៃស្ទាបថ្ពាស ហើយនិយាយប្រាប់នាងថា :

ទុបង់ក្ដុបទៅ វារវល់តែរៀបចំអាពាហ៍ពិពាហ៍ឲ្យនាក់ទើង គូដណ្ដឹងស្រី ដោយហេតុហ្នឹងហើយបានជាបាត់មិនឃើញមក ....

"ហ៊ឺៗ! គាត់ចេះចង់បានប្រពន្ធកូនដែរហ្ន៎?"

"ចុះវាជាមនុស្សទើងគេដែរតើ សូម្បីសត្វក៏គង់រកគូដែរ ព្រោះជាត

ផុតថ្ងៃកត្តិកហើយ ប្រពន្ធមានណាន់បងឲ្យគេខ្ញុំគេន បានពន្យល់ប្រាប់ ថាគ្មានខណៈណាឲ្យបានល្អជាងប្អូននេះគ្មានទេ . បងក៏ឃើញច្បាស់ដូចសំដីការមែន" ថាហើយអាចារ្យក៏សើច ឯនាងគ្រាន់តែញញឹមធ្វើយកថា :

"រូបគាត់ជាដូចម្ដេចទៀត?"

"នេះចាំបងដឹងនៅប៊ិនក្រោកដ កំសត់ហៅឬទេ បងគ្រាន់បន្ថែមពាក្យ ម៉ាប្អូនសម្រៃតែនឹងការទេ ប្អូនជាម៉េចហ៎?"

"ល្អហើយ តាមគាត់ថាពិតៗ អ្នកណាៈទៅត្រូវការនឹងមនុស្សពិត ចេះចិត្តបំផុតនោះ"

នាងបានឮពាក្យប្រយោគខាងក្រោយនេះ កើតហួសសេចក្ដីដែលត្រូវនិយាយ ពិតហើយថាជានាងជាត្រង់ ខាត់ខាងនឹងពិតនាងបានសំដែងសេចក្ដីបែបនោះ ដោយឥតញញើត តុកជាយ៉ាងណាក៏នាងកោនគិតដល់កំឡោះកំសត់ដែលធ្លាប់កើតទុក្ខព្រោះនាង ឥឡូវបើមានប្រពន្ធម្ដើរពាងើយគួរឲ្យអន់ចិត្តដែរ ឬទេព្រោះអ្វី? ត្រង់នេះនាងមិនហ៊ានថ្លែងបញ្ចេញឲ្យច្បាស់ហើយផែនគិតរឿងនោះតទៅទៀត ។ ឯគំនិតរបស់នាងនោះមិនកំបាំងដល់អាចារ្យឡើយ តែអាចារ្យហាស្ដីមិនទាន់ មានមនុស្សក្នុងផ្ទះមកប្រាប់ថា ម្ចាស់លោកខ្ញុំការនាក់ត្រូវការជួបនឹងអាចារ្យ ក៏ឲ្យហៅចូលមក អ្នកនោះឯងគឺជាជីវិតល្អស; កាលបើធ្វើការវេះចល់គ្នារួចហើយ អាចារ្យក៏សាកសួររឿងថា

“បើដូច្នោះ មានតែកាត់ទៅកេសរផ្កាឈូកបន្ទះណាកកក់កណ្ដាលផ្លិត, ចុះយើង ណាស់ ដូចម្ដេចក៏មិនប្រាប់ខ្ញុំឲ្យដឹងផង, យើងសោកក្រៀមចិត្តពីរឿងអី បានជាផលុំម្ល៉េះអេះ ឬមួយបានដំណឹងមកថា ម្ដាយឪពុកព្រមតាំង បងប្រុសស្លាប់បាត់ទៅហើយដឹង បានជាទៀយណាយរសិទចន់ស់នៅ ? ណ្ហើយអី បើដូច្នោះត្រូវទៅកាត់ ។

កាលបើអ្នកចាំទីពីរខ្លួលខ្លាយទៅរបស់សោកក្រៀវ ណាផ្ទះនក្រក៏វិល មកផ្ទះ ចាប់ចាក់គាយើតកទៅទៀត តែនាងកាប់ក្រឡាបេះតែកាន់ប្រឡៀ ដូបផ្កាមានគំនិតមួយផ្សេងក្រកពខមម្ដាបកន្ធូវក្បាលរបស់នាង ហើយ នាងដាក់ការចុះពីដៃទៅអន្ទុយនៅមាត់បង្អួច ក្រឡេកមើលទៅឃើញ ផ្កាកុឡាបហើយមិនរីកថី កើតកើបក្នុងចិត្តពុំដឹងជាដោយហេតុអ្វី នាងក៏សោក ស្ដាយផ្កាផលដួងចិត្តរបស់នាង ដល់សត្វរបស់នាង តែមិនបានការ មួយសន្ទុះ មានសំឡេងខ្សាវៗ ក្ដិ(តបែ)កហាក់ដូចជាមកពីកំបន់ឆ្ងាយ នាងផ្ទៀង ស្ដាប់ទៅក៏ឮសូរដូចមាត់គេចារក្សោសថា “អូនសមតែនឹកទេ អូនជា ដូចម្ដេចហើ” ពាក្យសូរនោះសមដូចសេចក្ដីសូរដែកបាំងរបស់នាងដែរ ។

ម្ដាសោកក្រៀមក៏សព្វមួយៗ ចេញពីផ្កាកុឡាបប្រាកដផលដែករបស់ នាង ហើយនាងឮសូរសំដីដំលុះនិយាយឡើងថា “ឪបងក្តើបទៅ កាលរៀបចំពីកាំនបំរុងគ្រាហ៍ពីពារហ៍ខ្លួនកំរិន្ទនស្រីថ្លៃខ្សូលូស ដោយហេតុ ហានហើយបានជាបាត់ចុះឃើញមក” ហើយនាងរំពឹងគិតថា ដោយហេតុ

តែសោភ័ក្ត្រស្មោះស្ម័គ្រនឹងកូនក្រមុំគេទេតើ បានជាបាក់ផែនឃើញមុខក្រមួននាងទៀត ហើយនឹងនឹងមួកខ្លួនជាបុគ្គលស្មោះត្រង់ គេគួរជឿទុកចិត្តនឹងសំដីប្រុសផ្តួចផ្តើមបាន បើលុះណាចៅអ៊ំករតែសត្វមេអំបៅផ្ទះបេះ; គួរឲ្យទ្រមើមទ្រមៃនពេក ។

ទុកជានាងគិតបែបណា ក៏គង់តែទកម្សាន្តដល់បុត្រថៃខ្សែល្អ ដែលសោភ័ក្ត្រត្រូវចិត្តជាងនាង ទើបកើតសេចក្តីប្រណែនចង់ឃើញស៊ីសង្គ្រាតេជាទីនេះតតាយយ៉ាងណាទៅ រួចចង់ឲ្យសោភ័ក្ត្របាត់ខ្លួនពីទីក្រុងទៅដោយអំណាចនាងស្អប់ ។

មួយសន្ទុះក្រោយមក ព្រួស្យសំឡេកមួយឡើងថា "យ៉ើអើសោភ័ក្ត្រខឹងចិត្តពីរឿងអ្វីបានជាផាត់ម៉្លេះអេះ" នាងក៏រន្ធត់អស់គន្ធប្រាពក ស្រពោនមុខមួយរំពេច ដោយទឹកឃើញថា សោភ័ក្ត្រប្រែហ៊ាលជាឈឺចិត្តព្រោះនាងមិនមើលមុខទេ ដឹងបានជាទៅសម្លាប់ខ្លួន ទុខ្លួននាងស្រពិត។ គួរឲ្យកោតនិកដល់សោភ័ក្ត្រណាស់ណាស់ អនិច្ចាអើយ សោភ័ក្ត្រស៊ូលះបង់ជីវិត ស៊ូលះបង់បុត្រថៃខ្សែល្អព្រោះសោកហួសដល់ខ្លួននាងដោយពិត ។

ឱសោភ័ក្ត្រស្រឡាញ់នាងមែន។ តែដែលបានជាទៅដណ្តឹងកូនថៃខ្សែល្អព្រោះតែសង្ស័យ លុះបានឃើញមុខនាងវិញក៏ដឹងខ្លួនថា គ្មាននរណាធ្វើឲ្យសប្បាយបានក្រៅពីរូបនាង ។ តែនាងមានះធ្វើឥតការ

ដល់សេចក្តីពេញចិត្តរបស់នាង ឡើងថា ណា ៗ ក៏នាងស្លាប់បាត់ទៅហើយ ពោះជារស់នៅក៏មិនជាការអ្វី គ្មានទាក់ទងរបស់នាងចន្ទិមបន្ទុចសោះ នាងក៏ដោរងគិតទៀត ។

នាងវិលត្រឡប់មកវាប់ករផ្ដើ តែចិត្តនៅទុំក្រោងចាំមើលផ្លូវអាចារ្យត្រឡប់មកវិញ ។

ចំណែកអាចារ្យ ទីងប៉ៃខ្វល់ល្ងួសនាំគ្នាស្វែងរកស្ពុងណាំងសោភ័ក្ត្រគ្រប់ផ្ទៃ តែគ្មានទីណាដឹងដំណឹងសោះ មានតែអ្នកជាក់ស៊ីក្ដាក់ដឹងថា សោភ័ក្ត្របានដើរតេសតតៈតម្រង់ទៅកំពង់ទឹក នារពេលម៉ោង ១២ យប់ ក្នុងខណៈដែលអ្នកជាក់ស៊ីក្ដាវិលត្រឡប់មកផ្ទះអាគារវិញ ព្រោះមេឃមិនស្រលហើយរលឹមបន្តិច ៗ ផង អ្នកចាំងតែកើតពស់បក្ខដើរតម្រង់ទៅឯមាត់ទន្លេ ទើបថាសោភ័ក្ត្រច្បាស់ជាបានទៅជាចំណីក្រពើបង្កងទៅហើយ ។

ដល់មាត់កំពង់ អាចារ្យប្រទះឃើញឈាមតកជាប់លើថ្មទីងលើស្មៅហូតដល់ទឹក ទើបដៅសេចក្តីប៉ាប់ថាខ្លួនស្មានថា ចំឃើញទេឈាមតកជាប់ក្នុងក្រញៀតថ្មនេះ ឡើងក្រហមព្រោះត្រកៀងលាង ហើយជាប់នៅតួពៈស្មៅគឺមានមនុស្សដួលត្រង់នេះ ចំប្រឹងប្រែងទីងងើបឡើងវិញ ព្រោះអស់កម្លាំងខ្លាំងណាស់ ហើយរមៀលសំដៅដំបូលក្នុងស្មៅកស់ណាមឈាមឲ្យដឹតជាប់នៅនោះ ដែលទឹកក្បៀងប្រាប់ពូលមិនដល់ ចាំមើលនោះមានក្ដុកកន្ត្រកក្ដុកមួយ ល្មមឃើញយកមកពិនិត្យមើល

គេជារបស់នរណា អាចារ្យរើសយកមកមើលឃើញមានអក្សរចាក់ជា អក្សរ "ស" និង "ប" ច្បាស់ណាស់ ដោយសេចក្ដីតក់ស្លុត គឺជាដៃនារីដែលចាក់ឲ្យគ្រូនេះ តែអាចារ្យគ្មានគ្រឿងសំគាល់ក៏ហុចឲ្យទៅជីខ្សែលួសៗ ទទួលយកទៅមើលហោង ក៏ស្រក់ទឹកភ្នែកតក់ៗ អាចារ្យសួរថា

"ជីចំណាំបានជារបស់អ្នកណាដែរឬ ? ដូចម្ដេចបានជាឃើញកូនកន្សែងនេះហើយយំ ? ប្រាប់ឲ្យខ្ញុំបានដឹងផង" ។

បាទខ្ញុំស្គាល់បាន . . . ជីខ្សែលួសអួលដើមកនិយាយស្ទើរមិនរួច ឈប់ស្ងៀមមួយស្របក់បាននិយាយតទៅទៀត: ខ្ញុំចាំបាន កូនកន្សែងនេះគឺរបស់ខ្ញុំបានចាក់ឲ្យសោភ័ក្ត្រទុកជារបស់បញ្ចាំចិត្ត ឥឡូវឃើញតែកន្សែង ឯរូបមនុស្សបាត់ទៅឯណាទៅ ឱពុំតោកម្សោយអើយ សោភ័ក្ត្រ... សោភ័ក្ត្រអើយម្ដេចមកចាកចោលយើងទៅស្រឡះចាំងស្រស់ដូច្នេះ មិនអាសូរដល់យើងកល់គ្នាដែលនៅឯក្រោយសោះ កូនមាសឪពុកៗ ស្មានជាបានពឹងកូនដល់ឪពុកចាស់ជរាទៅ ឥឡូវឪពុកកម្មទុក្ខព្រួយ ។

ជីខ្សែលួសយំខ្សឹកខ្សួលដូចកូនក្មេង ដោយស្រឡាញ់សោភ័ក្ត្រខ្លាំងណាស់ ចាំឲ្យអាចារ្យលើករលោងទឹកភ្នែក" ព្រាំទំនងសេចក្ដីទុក្ខរបស់ជីខ្សែលួសពុំបាន ចំណែកអាចារ្យក៏អាសូរសោភ័ក្ត្រដ៏ក្រៃលែងហើយ តែទំនងស្មាតើមើលកិច្ចការបច្ចុប្បន្នហេតុទៅទៀត ៖ ចុងបំផុតមុខអាចារ្យក៏កើតឡើងចិត្ត និយាយប្រាប់ជីខ្សែលួសថា

បើតាមខ្ញុំសង្កេត ខ្ញុំយល់ឃើញថា លោកគ្រូមិនរស់នៅកណ្ដាលមាត់ទន្លេទេ ព្រោះមានស្នាមជើងពីរគូដើរលើស្មៅដូចជះឃើញស្រាប់ ឯស្នាមជើងទាំងពីរគូនោះឃ្លាតឆ្ងាយពីគ្នាប្រហែលពីរជំហាន គឺថាមានមនុស្សពីរនាក់ បានវៃសំលោកគ្រូពីក្នុងទឹកយកឡើងទៅលើគោក ឯគ្រឿងជីវិតរបស់លោកគ្រូនោះខ្ញុំមិនបានងាកថានៅគង់នៅឡើយ ឬសាបសូន្យទៅហើយ យើងត្រូវស៊ើបសួរដំណឹងតទៅទៀត តែពេលនេះកាន់តែថ្ងៃណាស់ហើយ ។ មេឃក៏ពុំស្រលះផង ល្មមយើងទៅផ្ទះសិន ចាំល្ងាចទើបស៊ើបសួរតទៅទៀត ។

អ្នកទាំងពីរក៏បែកគ្នាទៅ ។ ដោយមានចិត្តត្រេកអរបន្តិច ថៃខៀវល្អស នាំសេចក្ដីនោះយកទៅជម្រាបប្រាប់គ្រួសាររបស់ខ្លួន និងសុំបុត្រលោកគ្រូ ហុចឲ្យបុត្រីសំឡាញ់ ។ ក៏ខ្ទង់អ.ប់អង្គុយចំផ្ទៃស្មារតីពុំទាន់ ក៏យំសោកជាច្រើន នាងខ្ញុំក្រលោកគ្រូថាពាក្យដូច្នេះ

“ ឱបងលោកគ្រូអើយ បងបាត់ពុំឃើញមកលេងជំនួនមួយយប់ទៀតហើយ ប្អូនស្មានថាបងរវល់រៀបចំសេចក្ដីសុខរបស់យើងតទៅថ្ងៃមុខ ប្អូនតែងតែនឹកដល់បងពុំដែលដាច់ ទំរោះបាក់ពុំចេះទៀតណាយ ព្រោះយល់ឃើញថាយើងនឹងបានសប្បាយក្នុងកាលមិនយូរប៉ុន្មាន មិនដឹងជាបងមកបាត់ពេលប្អូនទៅដូច្នេះសោះ គួរឲ្យអាណោចអាល័យអីម៉្លេះទេ

ក្តួចកន្សែងដែលខ្ញុំបានឲ្យទៅវង្សវិលត្រឡប់មកដល់ដៃខ្ញុំវិញពីក ឬជាសំណាងរបស់ខ្ញុំមិនត្រូវបានបងសោភ័ក្ត្រជាប្តី . . . "

រួចខ្មែរនរទ្ធិះខ្សែត្រឡាកក្តួលក្តខ៏ណាទទេពេដ្ឋក លើកាអ៊ី, ថៃខ្សែលួស ព្រមទាំងកិរិយាកិតកំបេ ស្ទះទៅថ្នាក់ថ្មកុគ្រិទ្ធយា យល្ងងលោមដោយពាក្យពីរោះបាប់ចិត្ត សុទ្យាចាំទីនីរកសោភ័ក្ត្រមកសងឲ្យនាងវិញ ទើបនាងងើបមុខឡើងតែបួលទៅកងបន្ទប់ បណ្តាយឲ្យខ្ញុំកញ្ជាំញញីតាមចិត្តដល់ហួសកំណត់ហើយ បានបើកសំបុត្រសោភ័ក្ត្រមើល, នាងមើលបណ្តើរយំបណ្តើរ នាងរៀបរាប់ពីកាលដែលបានជួបគ្នាពីមុនៗមក ដល់បប់សេចក្តីក្នុងសំបុត្រនាងក៏រំពឹងគិតឃើញថា សោភ័ក្ត្រពាក់ព្រាសបាកញ្ញាតិសន្តានបានជាទុក្ខខ្លាំងណាស់អត់ទ្រាំរស់នៅពុំកើត បានសុខលះបង់ជីវិត ប៉ុន្តែលះបង់នាងហោល តែនាងមកគិតឃើញថា ចុះមុនៗមិនកើតទុក្ខទេ ឬអ្វីបានជាសប្បាយសារសងជាមួយនាង ទើបនាងកើតសង្ស័យក្រែងមានហេតុអ្វីផ្សេងពីនោះទៀត ។

ផម្ភាអ្នកកើតទុក្ខ: ព្រោះអ្នកខ្វៃតែងតែជញ្ជឹងគិតគេដើមហេតុសេចក្តីក្តុកនោះពុំលតែឃើញ ទើបកេទជាស្ត្រីផងនិតាប់យល់ការទាំងនោះបានច្បាស់ជាងប្រុសទាំងឡាយណាស់ ក៏ឯហេតុប្រាកដដែលនាំឲ្យសោភ័ក្ត្រសំឡាប់ខ្លួននោះក៏មិនកំបាំងដល់បញ្ញារបស់នាងដែរ នាងជឿជាក់ថាសោភ័ក្ត្រមានចាប់ចិត្តនឹងនារីឯណាមួយហើយ តែមិនសម្រេចផ្លូវសេចក្តី

ប្រាថ្នាព្រោះខ្លួនក្រ ទើបថៃមកកេតនាងវិញ, ពីការចិត្តមុននោះច្បាស់ជាមានជួបនឹងគេដើមហើយ ។ មានខ្លាចគេខ្លាំងបានជាស៊ូលះបង់ជីវិត ។ ចុះភាគីប្រុសអើយ ប្រុសចិត្តមិនទាន់ទេតើ ឯងស្មានជាគេស្មោះស្ម័គ្រដោយស្លូតត្រង់ មិនដឹងគេមកប្រែកដើម្បីឲ្យស្រួលខ្លួនប៉ុណ្ណោះសោះ ពុំគួរហ៊ានឲ្យឯងខូចចិត្តខូចគំនិតអស់ ឱលោកគ្រូអើយ ខ្ញុំស្មានជាបងចិត្តស្មោះនឹងខ្ញុំ មិនដឹងជាមានគេឯទៀតនៅក្នុងចិត្តបងសោះ ។ ផ្កាកំផ្លែដែលលោកគ្រូបានឲ្យពីការពីថ្ងៃចូលឆ្នាំគ្មានទំនេរព្រោះនេះទេ តែដោយនាងពេញចិត្តនឹងលោកគ្រូក៏មិនបានជាគិត ។

នាងនឹកខ្ញាញ់ក្នុងចិត្តឥតឧបមា ស្ទុះឡើងទៅបោចកើបរបស់ដែលលោកគ្រូបានឲ្យនាងយកទៅបោលអស់ ។ រួចហើយទៅចួបនុពុតម្តាយថ្លែងសេចក្តីប្រាប់ដោយក្តៅចិត្តថា

"បើជាប៉ារកលោកគ្រូឃើញ ឲ្យប៉ាប្រាប់គាត់ផង កុំឲ្យគាត់មកចួបមុខនឹងខ្ញុំទៀត ខ្ញុំលែងរវល់ហើយ" ។

រួចនាងវិលមកបន្ទប់ ប្រាសលើគ្រែយំសោកជាច្រើន ។ នាងខឹងនឹងលោកគ្រូឥតគណនា ហើយគ្មានចាំគិតគួរយូរ នាងស្អប់លោកគ្រូឥតគណនា ហើយគ្មានចាំគិតគួរយូរ នាងស្អប់លោកគ្រូមួយរំពេច គឺស្អប់លែងបង់មើលមុខទៀត ៕

*

* *

វគ្គទី១១

# កណ្ដាលបត្តមុខ

កណ្ដាលបន្ទប់តូចមួយមានទូកញ្ចក់ជុំវិញ ទីនេះការប្រៀបធៀប បងប្អូនម៉ាមីងណាដនេត្រនារីមកប្រជុំគ្នាតែកព្វការផ្សេងៗ ការសន្ទនានោះទាក់ទងដល់អាចារ្យដែលអ្នកទាំងនោះត្រូវតាំងឃើញតែបគ្នា ណាដនេត្រនារីសាស័ព្ទអំពីគុណសម្បត្តិរបស់នាង ដោយពាក្យសរសើរយ៉ាងសមសួនធ្វើឲ្យអ្នកទាំងនោះចង់ស្គាល់អាចារ្យនាងតែខ្លាំងឡើង ខ្ញុំក៏សន្និដ្ឋានរូបអាចារ្យយ៉ាងនេះយ៉ាងនោះតាមមនោគតិរៀងៗខ្លួន ។

ប្អូនថាអ្នកអស់នោះមានឱកាសទំនងស្រេកបាន ព្រោះអាចារ្យបើករថយន្តទៅឈប់មុខផ្ទះណាដនេត្រនារី ហើយចុះដើរចូលទៅ ដល់ឃើញមានភ្ញៀវច្រើនរកបង្វិលត្រឡប់មកក្រៅ តែត្រូវម្ដាយនាងហៅឲ្យចូលទៅចូប ទើបណាដនេត្រផ្ដើមសេចក្ដីបកាន់រាប់អាចារ្យទំនងបងប្អូនម៉ាមីងរបស់នាង អ្នកទាំងនោះលាន់មាត់សរសើរតែបគ្នា ព្រោះអាចារ្យជាមនុស្សមានរបៀបរៀបរយសមរម្យណាស់ ។

នៅឆ្នាំមួយ បន្ទុះអាចារ្យក៏ហៅណាដនេត្រ

"ប្អូនរៀបខ្លួនទៅយកខ្យល់អាកាស"

ចានីញញឹមខ្ចួលក្បួលទៅក្នុង ផ្ទះទោតា:របលាបន្តិប្អូនម៉ាម៉ឺង ចេញទៅលេងជាមួយគាថាវៀ ។ ក៏មើករថយន្តទៅឈប់នៅមាត់ទន្លេ សំរាប់មើលទូកនាក់ មើលខ្សាច់មានស្មៅប្រែក់ព្រៃពីលើដៃជាស ។

ព្រះសូរ្យលេតបោតលើប្រាង្គគាថាវៀកាំងមើលទៅឆ្ងាយមើលសត្វខ្វែង ហើរទៀលផ្ទាត់ឯអាកាសសំឡឹងមើលត្រី ខ្ទះទៀងលោបរោបចំណាំស្មើ នឹងផ្ទាទឹក មើលតពាចសោតមួយៗ មើលទូកបើកគ្រាន់ឯនាយឯ:ណោះ គាល់តែក្តួចតិតផល់ណ្ហុយទេត្រៃវែលគន្ធយជិត ចំណែកនាងកាលបើ ឃ្លល់ត្រជាក់បះពាល់សព្ទសព៌ាង្គកាយ ក៏ព្រឺចិត្តញញឹមព្រាយទុបដៃ ប្ដូលគ្នា ផល់គាថាវៀនិយាយថា

“ប្អូនស្គាប់សំព្វលេត ហាក់ដូចជាសូមេទសុថ្ងៃ គួរឲ្យសង្វើម កទិប្ដាស៊ីម្ទះ នៅកណ្ដាលបាតទន្លេ ងងឹតស្ងួនឈើនេះ មិនដឹងជា ទូកនាក់ទីងអ្នកដោយសារបំនួនប៉ុន្មានទេទៅទីរលើនោះ ។

ណុជទេត្រតក់ស្ពត់ចិត្តមួយរំពេច ទំពមុខស្រទោទស្រពន់មិន ស្រស់ ព្រោះទីតដល់សោកគ្រែដែលបាក់កងឺរទេពាលពីប៉ុន្មានថ្ងៃនោះ មិនដឹងជាគេឃើញហើយឬនៅ តែនាងមិនហ៊ានសួរគាថាវៀព្រោះ ខ្លាចគេឡិន តែមិនដឹងអៀនពីរឿងអ្វី ពេះតែមានសេចក្ដីសង្ស័យ:មិន ដាច់ នាងទំនួងស្ងាត់តែធ្វើថែបដូចក់ហ៊ាសួរគាថាវៀថា:

"បង ចុះគាត់ដែលលង់ទឹកនោះ ហៅថាដូចម្ដេចទៅ?" ។

"នុ៎ះបងចង់ដឹងដែរឬអី? បងស្មានថាប្អូនមិនសួរនឹក ប្អូនថាមិននិយាយប្រាប់ ។

"អូបង ខ្ញុំសួរចុះដឹងទេ តែមានការអ្វីទេ ព្រោះដូចជាគាណិកគាដែរ គាត់ព្រាត់តែម៉ែគត់ តែប្ដូរយកមោបមកពោលទៅស្រុកគេ" ។

គាណិកគាត់ធ្វើអី អាមនុស្សស្រស់ឡាប់ខ្លួនមិនគាប់ប្រសើរទេ មិនគួរទទឹងទឹកនាងផង ប្អូនយល់ឃើញដូចម្ដេច?" ។

"ចាស ខ្ញុំយល់ឃើញដូចបងដែរ នុ៎ះគាត់ស្លាប់បាត់ទៅហើយ?" ។

សំនៀងនាងចេញញាប់ចុះ ទើបនាងឈប់លែងនិយាយតទៅទៀត ទៀតមើលមាឃមើលអាឃេបបាត់សេចក្ដីគិតនោះបង់ ។ មួយសន្ទុះក្រោយមកនាងក៏ទៀងសួរកាពារប្រៀងថា

"បងចង់ទៅលេងខ្សាច់ដែរឬអី?" ។

"បងមិនបេះហៀលទេប្អូន បងខ្វាបលង់កណ្ដាលទឹក ខានឃើញមុខប្អូនទៅ" ។

"ចុះខ្ញុំសុខតែបេះហៀល ស្រែកម៉ាត់ដូលទូកគេមួយ ដល់ម៉ោង ៤ នាំគ្នាទៅបាយយកទៅញ៉ាំលើកោះខ្សាច់ បងអញ្ជើញទៅលេងជាមួយនឹងខ្ញុំផងណា នាងយកដៃអង្អែលស្មាកាពារយ៉ាងថ្នមហើយបញ្ចប់សេចក្ដីថាតែមិនព្រម ណុំនេះត្រូវដឹងនឹងបងហើយ" ។

អាចារ្យយកដៃអង្អែលសក់ក្បាលនាងយ៉ាងថ្នម ហើយពោលពាក្យដ៏ពីរោះចាប់ចិត្តទៅកាន់នាងវិញ :

“បងស្តាយណាស់ប្អូន ដោយមិនបានបំពេញអធ្យាស្រ័យរបស់អូន ព្រោះស្អែកបងមានកិច្ចរវល់ច្រើនណាស់ រកធ្វៀតដើរលេងមិនកើត ហើយចាំថ្ងៃក្រោយចុះ កុំខឹងនឹងបងអី ណាដួងនេត្រផងបងណា៎” ។

ណាដួងនេត្រមុខក្រញូវបន្តិច ឯអាចារ្យបើករថយន្តចេញពីនោះវិលមកផ្ទះវិញ បរសន្សឹមៗងាកមើលនាយកាយ លុះដល់ផ្លូវលក់កាហ្វេនៅជិតហាងផ៉ុន អាចារ្យក៏ឈប់រថយន្តមើលទៅក្នុងផ្ទះនោះ ដោយសេចក្តីអាណិតអាសូរ ។

នៅលើតុពេញទៅដោយកែវនិងសំបកដបស្រាបៀរ: បុរសម្នាក់មុខក្រហមឆ្អឹលភ្នែកឡើងស្អាប់ សណ្តូកដៃស្តាំលើតុ បត់ជើងកើយ យូរៗ លូកម្តងៗ ជាការការអ្នកស្រវឹងថ្នាំង ទោះអាវប្រឡាក់ប្រឡូសអស់គ្មានសល់ ពុំកាយស្មមស្គាំងស្លេកស្លាំងក្រក់មើលក្រៃលែង ដូចជាសាកអសុក ។

“បង៎ គាត់ខឹងដូចម្តេចបានជាផឹកស្រាដូច្នេះ ណាដួងនេត្រលើកចិញ្ចើម ឬ គាត់ជួបការវិបត្តិអ្វី?” ។

“ប្អូន តាមបងសង្កេតមកឃើញថាវាជាមនុស្សត្រឹមត្រូវល្អណាស់ ក៏ព្រោះមានយោគជាអ្នកមានពូជ មិនដែលចេះដើរលេងថ្ងៃថ្ងោរដោយផ្សារ

សោះ ហើយមិនបេះមានគុំគៀនដើរលេងទេ មិនដឹងជាហេតុដូចម្ដេចបាន ជាមកប្រែប្រព្រឹត្តស្រុកបែបនេះ ប្រហែលជាកន្ទួលចិត្តពីរឿងអ្វីហើយមើលទៅផ្ទុំនជាផលម្ទេះ" ។

"បុះបងមានប្រសាសន៍ថាស្លាប់ទៅហើយកាលអម្បាញ់មិញ បងកន្ទុំលេងទេបើដូច្នោះ" ។

"បងមិនបេះនិយាយពាក្យកុហកទេប្អូន ក៏ស្លាប់មែន គឺថាហ៊ុកឈ្មោះសំឡេងពីចិត្តរបស់ប្អូនជាកាបទៅ ដោយប្អូនលែងទឹកឃើញមុខធាក់ទៀត, ក៏បាននិយាយប្រាប់បងពីថ្ងៃមុននោះ ។ ដែលកក៏ឃើញគឺបងបានទៅសុំឋស្លូរនៅឯមន្ទីរពេទ្យ ពួកអ្នកព្យាបាលបាននិយាយប្រាប់បងថា ក៏ពេះតែអន្ទីរគេឯងឲ្យបណ្ដោយកាមកម្មទៅចុះ ក៏មិនបង់ស៊ីនៅទេ ដល់បងសួរក៏ប្រាប់ថា កើតទុក្ខណា សំតែក៏មិនបានប្រាប់បងថាកើតទុក្ខអំពីរឿងអ្វី តែះណ្ហែយចុះយើងកុំរវល់អ្វី តាមតែក៏ទៅចុះ" ។

ណុជនេត្រងាកមុខចេញទំនងដូចពេចមាត់ហើយ យកក្បូនកន្សែងចុកច្រមុះ ប្អូនជាអ្នកប្រមឹក់នោះក្រលេកមកឃើញក៏ស្លុតចិត្ត ដល់ថេយន្តកាបារ្យហួសទៅហើយ ទឹកភ្នែកក៏ហូរស្រណោះចេញមកលើមុខផ្អឹង សោ-ភ័ក្ត្រក្រាបមុខលើដៃយំខ្សឹកខ្សួលអស់កាលជាយូរ ដល់ងើបមុខឡើងវិញក៏ស្រែកប្រាប់អ្នកបំរើឲ្យយកស្រាមួយដបមកទៀត ចាក់ស៊ុកកូនកែវហើយសំឡឹងមើលពពុះកែវឆ្ងៀង សោភ័ក្ត្រកែកចិត្តសើចហាហាយ

វិស័យមនុស្សជួត  នៅពេលនោះមានគេទះស្មាពីក្រោយ  លោកគ្រូងាកមុខមើលឃើញថាប្រុសខ្លួន ។ហើយងើបឡើងគួរសម  តែជើងញ័រពេកក៏អង្គុយចុះទៅវិញ  មុខញញឹមសើចហ៊ឹៗ ។

“ជីអញ្ជើញពិសាស្រាជាមួយនឹងខ្ញុំ” ។

ជីនោះគ្រវីក្បាលហួសហេតុ  ទាញកៅអីអង្គុយជិតឲ្យជម្ពាន ដល់លោកគ្រូថា :

“ក្មួយ!  ក្មួយឯងក្រណាស់សព្វថ្ងៃ  ពុំសូវមានគេកប់ទេ  បើឯងប្រព្រឹត្តស្ពពន្ធនោះ  គេរឹតតែស្អប់ខ្ពើមថែមទៀត  ហើយឈប់ប៉ុណ្ណឹងចុះ  ឯងគិតមើល  បើឯងស្រវឹងព្រឹកល្ងាច  មុខជាលោកធំបណ្ដេញលែងឲ្យធ្វើការមិនខានទេ  មាជួយឯងក៏ពុំបាន  អម្បាញ់មិញនេះបាក់ងហៅចូលទៅគិតម្តងរួចទៅហើយ  ព្រោះតែរឿងឯង  ម៉េចក្មួយល្ងមប៉ុណ្ណឹងហើយបុអ៊ី ?” ។

លោកមាខ្ញុំនេះ . . . ខ្ញុំខ្ញុំលែងទទួល . . . ទទួលទានស្រាមិនបានទេតានប្រាស  រួចក៏សើចហ៊ឹៗ  គេដេញក៏ដេញទៅចុះ  ខ្ញុំបាចងាប់ទឹង . . . ទឹកដីកហើយជយោស្រាបៃយ៉ៅ  ។

ខ្លួនលោកគ្រូទ្រេតចុះឡើងផ្ដួលដេកលើតុទៀត  មាត់និយាយបំបាច់តែមិនបានសេចក្ដីថាអ្វី ជីនោះអស់ចិត្តក្រោកឡើងដកដង្ហើមធំដោយសេចក្ដីមេត្តា  គ្រវីក្បាលម្ដងទៀតទើបចេញពីផ្ទះនោះ  ដល់ផ្លូវហើយ

នៅតែងាកមើលមុខទៀត ដូចជាមិនអស់ចិត្តសោះ ក្រោយមក ទើបនិយាយចេញមកថា

«ឱទេវតាអើយ! ខ្ញុំពាល់ប៉ះតិកហើយ មិនគួរសោះមនុស្សបែបកយនេះមកផ្ចិតស្រាដូច្នេះ ធ្វើម្ដេចកម្លាំងឯងនឹងចាញ់ឲ្យវាមានវាបាន. បុរសកូនក្រមុំឲ្យវា ផ្ទះរបស់យើងនេះមានតែឲ្យទៅគេទៅ ខុចប្រុសក្រង់រ៉ះព្រោះ អំបីងតើបានជាមិនានរ៉ាមិនឲ្យចេញឈ្មោះសោភ័ក្រ្តទៀត» រួចគាត់ដកដង្ហើមយ៉ាងវែងដើរចេញទៅ ។

ចំណែកសោភ័ក្រ្ត កាលបើចំហាយសុរាក្រុកនពេញខ្លួនហើយនឹងមុខទន់ខ្លួនដេកកើយលើដៃម្ខាង យោលខ្លួនចុះឡើងមួយស្របក់បានដួលចុះ ដេកលក់ដូចមនុស្សស្លាប់លែងដឹងខ្លួន ។

យប់នោះឯងពពកខ្មៅធំៗ សាត់មកបាំងព្រះចន្ទជុំជិត កើតងងឹតព្រឹលៗ មើលមើលអ្វីពុំច្បាស់ នាំឲ្យអផ្សុកក្នុងចិត្តពន់ពេក សោភ័ក្រ្តសន្ធឹកផ្ទាល់រូបខ្លួនអនេកអនន្ត ងើយមុខមើលចន្ទមណ្ឌលដែលឃើញព្រាលៗ ទឹកសន្សើមជាប់ហានះរបស់ខ្លួន រួចគិតដល់សេចក្ដីក្នុងរឿងសេដ្ឋីកំណាញ់ដែលខ្លួនបានមើលកាលនៅរៀនអក្សរនៅឡើយ ទើបគិតឃើញថា សក្ការអញនេះក៏ដូចមាណពទេវទិន្នមិត្រ ដែលកន្ទក់កន្ទេញចង់បានព្រះចន្ទយកមកធ្វើជាចង្កៀងនោះឯង សមដូចសំដីសេដ្ឋីកំណាញ់ដែលបានបន្ទោសដល់ទេវញាណពនោះថា: (មានត)

ឯកសហស្សរាត្រី

មួយពាន់មួយយប់ (ជារឿងអារ៉ាប់)

ភាគទី ១២

លោក ប៊ុយ-ប៊ុនស្រូវ ប្រែចេញពីភាសាបារាំងសែសមកជាខេមរភាសា

(កាលលោកនៅធ្វើការក្នុងក្រសួងពុទ្ធសាសនបណ្ឌិត្យ)

---

# រឿងសិន្ទបាដអ្នកដើរសមុទ្រ

ចាន់សែរ៉ាសាដក្រាបទូលថា បពិត្រព្រះករុណាជាអម្ចាស់ជីវិតលើត្បូង, កាលក្នុងរជ្ជព្រះចៅហារុន-អាល់-រ៉ាជិត ដែលខ្ញុំម្ចាស់ទើបនឹងពណ៌នាមកនេះ មានបុរសកំសត់ម្នាក់ឈ្មោះហិន្ទបាដ ជាអ្នកស៊ីឈ្នួលលីកទូលខ្សែក្នុងក្រុងបាគដាដ ។ ថ្ងៃមួយ បុរសនោះលីកគ្រឿងធ្ងន់ ពីចុងក្រុងម្ខាងទៅចុងក្រុងម្ខាង, ពេលនោះ ក្តៅខ្លាំងផងចាំងថ្ងៃ ក៏នៅវែងឆ្ងាយទៅទៀត ហិន្ទបាដអស់កំលាំងណាស់ ទើបដាក់អម្រែក ហើយឈប់សម្រាកក្បែរចិញ្ចើមថ្នល់ ប៉ះប៉ើតទីផ្ទះធំដ៏ស្កុសស្កម្ភជាទីមានខ្យល់ត្រជាក់បក់រំភើយ ៗ ។

ក្លិនគ្រឿងក្រអូបផ្សេង ៗ សាយចេញមកតាមបង្អួចផ្ទះនោះ ជុំក្រអូបឈ្ងុយឈប់ ហើយបុរសនោះបានឮសូរស័ព្ទតូរ្យតន្ត្រីចំរៀងផង ព្រមទាំងមានសំឡេងសត្វពីរេចពីរោច ទីទីសត្វឯទៀត ៗ ដែលនៅក្នុងក្រុងបាគដាដ បើតាត្រៀបតាមផង, សូរស័ព្ទតូរ្យតន្ត្រីនឹងក្លិន

សាច់អាំងចៀន ជាហេតុនាំឲ្យបុរសនោះនឹកថា គេកំពុងជប់លៀងគ្នាដោយការផឹកស៊ីហាក់នៅក្នុងផ្ទះនោះឯង ។ ហិន្ទូបាទចង់ស្គាល់ម្ចាស់ផ្ទះនោះណាស់ ក៏ប្រថុយចូលទៅសួរមនុស្សបំរើ ដែលស្លៀកពាក់ស្អាតបាត ហើយឈរត្រៀមចាំនៅមុខខ្លះ ៗ ពួកមនុស្សបម្រើឆ្លើយតបមកវិញដោយពាក្យចំអកថា "អើ! អ្នកនៅក្នុងក្រុងបានដាច់ ម្តេចក៏មិនស្គាល់លោកមហាសេដ្ឋី សិន្ទូបាទ? លោកនេះ មានឈ្មោះល្បីល្បាញយ៉ាងក្រៀវក្រាខាងការធ្វើដំណើរតាមសមុទ្រ" ហិន្ទូបាទ លុះបានដឹងជាច្បាស់ជាផ្ទះរបស់មហាសេដ្ឋី សិន្ទូបាទដូច្នោះហើយ ក៏គាំងមានសេចក្តីប្រណែនឫស្យា ព្រោះខ្លួនឯងជាអ្នកក្រីក្រលំបាកថោកទាប ទឹកសព្វៗ ទៅមានសេចក្តីទោមនស្សក្តួលចិត្តពន់ពេក ទើបស្រែកនិយាយពេញទំហឹងថា: 'ឱព្រះម្ចាស់ថ្លៃអើយ! ម្តេចឡើយក៏មិនទតមើលឲ្យច្បាស់ តើខ្ញុំនិងលោកសេដ្ឋីសិន្ទូបាទ មានវាសនាខុសគ្នាយ៉ាងណាទៅ, កល់តែថ្ងៃខ្ញុំខំប្រឹងប្រែងធ្វើការគេស៊ីឈ្នួលហត់ពេញអស់ទាំងខ្លួន ចិញ្ចឹមជីវិតនឹងត្រសាបានដោយត្រដាបត្រដួស ស្ទើរតែមិនបានពេញលេញគ្រប់គ្រាន់ផង ហើយបរិភោគតែត្រឹមនំបុ័ងដែលគេមិនត្រូវការ, ចំណែកលោកសិន្ទូបាទវិញ ចាយវាយស៊ីផឹកសប្បាយពេញបន្ទុកតាមអំពើចិត្ត ចុះគេបានធ្វើអំពើយ៉ាងណាខ្លះ បានជាមានវាសនាថ្លៃថ្លាខ្ពង់ខ្ពស់ដល់ម្ល៉េះ? ត្រង់ខ្ញុំនេះ ព្រោះហេតុអ្វីបានជាក្រីក្រថោកទាបបែបនេះ?" កាលពេល

ពាក្យនេះចប់ហើយ, បុរសនោះ ក៏តាំងទ្រឹងធ្វើកិរិយាចាក់ដូចជាមនុស្សដែលមានទុក្ខខ្លាំង ហើយគ្មានសេចក្តីសង្ឃឹមសោះ ។

ពេលនោះ គាប់ជួនជាលោកសិទ្ធបាដ កំពុងតែដើរលំហើយខ្លួននៅក្បែរថ្នល់ បានឮបុរសនោះពោលនូវពាក្យប្រកបដោយសេចក្តីទុក្ខពិតដូច្នោះ ក៏ប្រើបម្រើម្នាក់ឲ្យទៅហៅហរិទ្ធបាដ ឲ្យចូលមកជួបប្រទល់មុខនឹងលោក ។ បុរសស៊ីឈ្នួលកំពុងតែតក់ស្លុតឡើងៗ ស្រាប់តែឃើញបម្រើម្នាក់ដើរចេញពីផ្ទះ តម្រង់មករកខ្លួន ចាប់ទាញដៃហើយនិយាយថា: "ដើរតាមខ្ញុំមក លោកសេដ្ឋីជាចៅហ្វាយយើង ត្រូវការនិយាយនឹងអ្នកឯងបន្តិច" ។

ហរិទ្ធបាដ មានសេចក្តីងឿងឆ្ងល់នឹងការរកហៅរបស់សេដ្ឋីណាស់ ហើយមានសេចក្តីសង្ស័យថា "ប្រហែលជាសេដ្ឋីហៅខ្លួនទៅ ដើម្បីនឹងនិយាយផ្តាញ់ផ្តាលទេដឹង" ទើបនិយាយដោះដៃអង្វរគេបម្រើនោះថា ខ្លួនពេលអាប្រែកទុកនៅក្បែរថ្នល់ឯណោះ នឹងទៅជាមួយពុំបានទេ, តែអ្នកបម្រើនិយាយអះអាងថានឹងទទួលថែរក្សាមើលឲ្យ ហើយបង្ខំឲ្យបុរសនោះចូលទៅ ។

បំរើនោះដឹកដៃបុរសអ្នកស៊ីឈ្នួលចូលទៅក្នុងបន្ទប់មួយធំ ដែលមានមនុស្សច្រើនអង្គុយជុំវិញតុ ១ ហើយលើតុនោះរៀបដាក់សុទ្ធសឹងតែម្ហូបយ៉ាងក្រាល ។ ឃើញមនុស្សជាន់ខ្ពស់ម្នាក់អង្គុយត្រង់កន្លែង

ដាក់ក្ដួយស មានឫកពាថ្លៃថ្នូរ រូបឆោមទ្រង់ទ្រាយបើសមរម្យមានពុកមាត់សវែង គួរឲ្យគេគោរពកោតក្រែង ។ នៅពីខាងក្រោយខ្នងលោកមានពាហានទីនមនុស្សបម្រើជាច្រើន ឈរត្រៀបត្រាដោយបំរុងខ្លួនទីនបម្រើ. មនុស្សជាន់ខ្ពស់នេះ គឺលោកសិទ្ធុបាទ ។ បុរសហិទ្ធុបាទលើកដៃគំនាប់ញញើញញើរ ដោយឃើញមនុស្សច្រើនដេរដាសពាសពេញទីនគោជនាហារដ៏វិសេសថ្លៃថ្លា; លោកសិទ្ធុបាទ រៀបចំឲ្យហិទ្ធុបាទគង់យុខាងស្ដាំ ហើយចាត់ចែងឲ្យបរិភោគដោយដៃឯងយកស្រាទំពាំងជូរយ៉ាងមានទុជារសមគួរចាក់ឲ្យផឹក ។

លុះដល់បរិភោគរួចស្រេចហើយ ទើបលោកសិទ្ធុបាទចាប់ផ្ដើមសួរឈ្មោះ ទីនវេរកស៊ីរបស់ហិទ្ធុបាទៗឆ្លើយដំកបសព្វគ្រប់តាមពាក្យដែលសួរ; លោកសិទ្ធុបាទសួរគេទៅទៀតថា: "ខ្ញុំចង់ដឹងណាស់ កាលដែលអ្នកឈប់សម្រាកក្បែរបរិវេណមាត់ទ្វារនោះ តើអ្នកពោលពាក្យដូចម្ដេចខ្លះ" ។

កាលបានឮពាក្យសួរដេញដោលដូច្នោះហើយ ហិទ្ធុបាទក៏ភិតភ័យញ័ររន្ធត់ជាកម្មផ្ទៃ និយាយឆ្លើយដំណាលដោយពាក្យអង្វរថា: "ឱលោកម្ចាស់ថ្លៃខ្ញុំអើយ! ដោយខ្ញុំព្រះបាទនឿយហត់ពន់ពេក ទើបមាត់ខ្ញុំព្រះបាទឲ្យភ្លាយបញ្ចេញនូវពាក្យអសប្បុរសដូច្នោះឯង, សូមព្រះគុណម្ចាស់ មេត្តាអត់ទោសប្រោសប្រណីឲ្យបាន" ។ សេដ្ឋីឆ្លើយថា: "នែបុរសកំសត់ ចូរអ្នកឯងកុំស្លុតចិត្ត យើងមិនចាប់ទោសអ្នកដំណើរគេឡើង

ហេតុអ្នកឯង ដោយឥតបើគិតដូច្នោះឡើយ, យើងមិនបន្ទោសបង្អាប់អ្នកឯងទេ យើងករុណាអ្នកឯងណាស់ ប៉ុន្តែយើងត្រូវតែទាញអ្នកឯងចេញអំពីសេចក្តីក័ន្ទប្រទាំ ដែលអ្នកឯងហាក់ដូចជាមានចំពោះមកលើខ្លួនយើង អ្នកឯងប្រហែលជាស្មានថា ខ្ញុំដែលមានភោគសម្បត្តិទាំងអម្បាលម៉ាននេះ ដោយឥតបើមានខំប្រឹងប្រែងទៀត ព្រោយទីងទំលេស៊ីធ្វើការស្អីសោះ, អ្នកកុំបីងឿងឆ្ងល់ឡើយ ខ្ញុំបានខំធ្វើការរកស៊ីដោយកំឡាំងនឹងដំរិះប្រាជ្ញទៀត ព្រោយលំបាកជាយូរឆ្នាំណាស់ ៗ ពិតប្រាកដមែន សូមអស់លោកជ្រាបចុះ ការដែលខ្ញុំបានកាប់ទាំងអម្បាលម៉ាន សុទ្ធតែជាហើយលំបាកហើងសំបើមណាស់, ទោះបីជនឯណាដែលត្រៀវត្រាយ៉ាងចំណាន អើគង់តែពុញព្រាន់ញុកនឹងការជូនសមុទ្រទៅរកផលប្រយោជន៍នោះដែរ, ខ្ញុំបានប្រទះគ្រោះថ្នាក់ដ៏ធំអស្ចារ្យដែលខ្ញុំគួរអស់ចិត្ត ក្នុងគ្រាដែលខ្ញុំបានជួងសមុទ្រអស់ពារៈ ៧ ដង ៗ ដោយនូសារនេះជាមន្ទិលដោតជ័យល្អ ខ្ញុំនឹងអធិប្បាយរឿងនេះជូនអស់លោកស្តាប់, ប្រហែលជាអស់លោកមិនពុញព្រាន់នឹងស្តាប់ទេមើលទៅ ៗ

## ដំណើរទី ១ របស់ស៊ិន្ទបាដអ្នកដើរសមុទ្រ

កាលដែលមាតាបិតាខ្ញុំទទួលអនិច្ចកម្មទៅ គាត់បានទុកកេរ្តិ៍មតកឲ្យខ្ញុំជាច្រើន ៗ ដោយខ្ញុំនៅក្មេង ខ្ញុំប្រើប្រាស់ចាយវាយទ្រព្យសម្បត្តិនោះ តាមអំណាចចិត្តពាលព្រេលផ្តេសផ្តាស រកលេងនឹងលេងសើ

ដកអស់ ។ តែយូរបន្តិចមក ខ្ញុំក៏បានភ្ញាក់ស្មារតីឡើងវិញថា គ្រឿងកក បើយើងមិនចេះថែរក្សាទេ នឹងវិនាសអន្តរាយទៅវិញពុំខាន, ឯកិរិយាអាក្រក់ដែលខ្ញុំបានប្រព្រឹត្តកន្លងមកនោះ ជាហេតុនាំឲ្យខ្ញុំខាតពេលវេលាដែលមានដម្លៃជាទីបំផុត, ខ្ញុំសំគាល់ឃើញថា សេចក្ដីវេទនាធំនឹងមានដល់មនុស្សគ្រប់ពេលចាស់ជរានឹងក្រីក្រ ។ ខ្ញុំបាននឹកឃើញពាក្យអ្នកប្រាជ្ញម្នាក់ឈ្មោះសាឡូម៉ុង ដំណាលទុកថា: " ស៊ូឲ្យស្លាប់ ប្រសើរជាជាងរស់នៅក្រលំបាក" ។

ដោយគិតឃើញសព្វគ្រប់ដូច្នោះហើយ ខ្ញុំក៏តាំងរកប្រែប្រួលផ្សំទ្រព្យសម្បត្តិដែលនៅសល់ យកទៅលក់ឲ្យយន្យនកណ្ដាលផ្សារ ហើយខ្ញុំសេពគប់នឹងពួកឈ្មួញខ្លះ ដែលអាចនឹងបំភ្លឺផ្លូវខ្ញុំបាន, ខ្ញុំប្រុងនឹងយកលុយកាក់ដែលសល់បន្តិចបន្តួច ទៅធ្វើជំនួញជួញប្រែដើម្បីយកផលប្រយោជន៍ទៅមុខ, កាលបើខ្ញុំគិតឃើញឧបាយយ៉ាងនេះហើយ ខ្ញុំក៏តាំងចាប់ផ្ដើមធ្វើការ ។ ខ្ញុំចុះទៅក្រុងបាល់ស្បូ ហើយបើកសំពៅចេញទៅជាមួយនឹងពួកឈ្មួញឯទៀតជាច្រើន, សំពៅនោះយើងបានចូលហ៊ុនស្មើភាគគ្នា ។

យើងបើកសំពៅត្រង់ទៅប្រទេសឥណ្ឌា បើកទៅទិសកើត តាមឈូងសមុទ្រប៉ែរ្ស ដែលមានស្រុកអារ៉ាប់នៅខាងស្ដាំ មានក្រុងប៉ែរ្សនៅខាងឆ្វេង, ចេញផុតពីសមុទ្រប៉ែរ្ស យើងបើកសំពៅទៅតាមសមុទ្រឥណ្ឌា

ដំណើរល្បីល្បាយ ៗ ដើមដំបូងខ្ញុំពុលរលក តែធាប់បានស្រួលឡើងវិញ, ចាប់តាំងពីថ្ងៃនោះមក ខ្ញុំបេះតែមានសេចក្ដីសុខសប្បាយជាដរាប ៗ យើងបានចូលចតតាមកោះជាច្រើនហែ ៗ តាមផ្លូវ ដើម្បីលក់ដូរទំនិញរបស់យើង ៗ ថ្ងៃមួយយើងកំពុងតែបើកសំពៅ ស្រាប់តែស្ងប់ខ្យល់ឈឹង ហើយយើងចតសំពៅនៅក្បែរកោះតូចមួយ ដែលទាបពេកប្រហាក់ទឹងទឹកមានសភាពហាក់ដូចជាវាលស្មៅ ហើយមានពណ៌ខៀវស្រងាត់, នាយកម្រួតសំពៅឲ្យដាក់ក្ដោងចុះ ហើយបើកអំណាចឲ្យពួកអ្នកសំពៅឡើងទៅលេងកោះនោះ ៗ ខ្ញុំឡើងទៅជាមួយនឹងគេដែរ; ប៉ុន្តែក្នុងពេលដែលយើងកំពុងតែស៊ីផឹកសប្បាយ ស្រាប់តែកោះកម្រើកញាប់ញ័រឡើង ៗ

ពួកអ្នកដែលនៅលើសំពៅ ស្រែកហៅឲ្យយើងចុះសំពៅវិញប្រញាប់ តែបណ្ដោយបណ្ដាយមុខជានឹងដល់នូវសេចក្ដីស្លាប់ទាំងអស់គ្នាពុំខាន; កោះនោះគឺខ្នងត្រីបាឡែន, ពួកខ្លះក៏រួសរាន់ឡើងសំពៅទាន់ ពួកខ្លះទៀតក៏លោតហែលក្នុងសមុទ្រ ចំណែកខ្ញុំនៅជិះលើខ្នងត្រីបាឡែន, លុះពេលដែលត្រីបាឡែនមុជទៅក្នុងទឹក ខ្ញុំស្ទុះប្រញាប់ប្រញាល់ទៅចាប់គល់ឈើ ១ ដែលគេយកពីសំពៅទៅសម្រាប់ដុត ៗ ខ្ញុំខំហែលទៅរកសំពៅ, ប៉ុន្តែចាប់ជួនជាពេលនោះមានខ្យល់ស្រួល ទើបនាយកម្រួតសំពៅឲ្យគេបើកសំពៅចេញចោលខ្ញុំទៅទុកខ្ញុំឲ្យនៅកណ្ដាលសមុទ្រតែម្នាក់ឯង ៗ

ខ្ញុំរសាត់ទៅតាមរលក ប្រឹងហែលទាំងយប់ទាំងថ្ងៃ ឥតសង្ឃឹមថានឹងបានរួចអំពីសេចក្តីស្លាប់សោះ ស្រាប់តែមានរលក ១ ធំបោកបន្ទ្រាក់ខ្ញុំទៅប៉ះនឹងច្រាំងកោះ ១ ដែលមានច្រាំងខ្ពស់ពេក ហើយលំបាកនឹងឡើងទៅដល់គោកខាងលើ បើប្រសិនជាគ្មានឫសឈើខ្លះ ដែលដុះឡើងសៀកសឹកនឹងថ្មតាមមាត់ច្រាំងនោះ ខ្ញុំប្រហែលជាឡើងទៅលើកោះនោះមិនរួចទេ ។ ខ្ញុំអស់កំលាំងហត់ហែលទន់ដៃទន់ជើង ដេកដ្រលៀកស្តូកស្តឹងលើផែនដី រហូតដល់ព្រឹកព្រាងថ្ងៃរះពេញពន្លឺ ។

ខ្ញុំមានសេចក្តីស្រេកឃ្លានខ្លាំង ព្រោះអត់អាហារមកជាយូរថ្ងៃហើយ ខ្ញុំត្រេតត្រដរួតទៅដកឫសស្មៅណា ដែលល្មមបរិភោគជំនួសអាហារបាន, ខ្ញុំបានប្រទះអណ្តូងទឹកសាបមួយ, លុះបានផឹកទឹកនោះរួចហើយ ទើបមានកំលាំងកំហែងគ្រាន់បើ, ខ្ញុំក៏ដើររុករកលើកោះនោះ ក្រែងលោបានជួបប្រទះនឹងមនុស្សណាមួយ ខ្ញុំបានចេញទៅកន្ទ្រាលមួយធំ បានឃើញសេះញីមួយកំពុងឈរស៊ីស្មៅ ខ្ញុំក៏ដើរតម្រង់ចូលទៅជិតមានសេចក្តីភ័យអរ ៗ ព្រោះមិនដឹងថាបានជួបប្រទះនឹងសេចក្តីសុខទុក្ខយ៉ាងណា មេសេះនោះមានរូបរាងស្អាតបាត ចងនឹងបង្គោលមួយ ។ ខ្ញុំកំពុងតែសង្កេតមើលសេះនោះ ស្រាប់តែឮស្នូរមាត់មនុស្សនិយាយគ្នាក្នុងរូងដី; លុះតមកមួយស្របក់ មនុស្សម្នាក់ចេញពីរូងដីដើរតម្រង់មករកខ្ញុំ ហើយបានសាកសួរដំណើររឿងហេតុរបស់ខ្ញុំសព្វគ្រប់ រួចហើយក៏ដឹកដៃខ្ញុំ

ដើរបបួលទៅក្នុងរូងដីនោះវិញ ។ ក្នុងទីនោះមានមនុស្សឯទៀតជាច្រើន អ្នកទាំងអស់នោះមានសេចក្ដីងឿងឆ្ងល់នឹងខ្ញុំណាស់ ដោយឃើញខ្ញុំនៅត្រមោចតែម្នាក់ឯងលើកោះនេះ ។ អ្នកខ្លះរៀបចំអាហារបន្តិចបន្តួចឲ្យខ្ញុំបរិភោគ, កាលបើបានកំលាំងពលំគ្រាន់បើហើយ ខ្ញុំក៏សាកសួរទៅអ្នកទាំងអស់នោះថា ដែលនាំគ្នាមកពួននៅរូងដីនេះ តើដើម្បីប្រយោជន៍អ្វី ? គេបាននិយាយរៀបរាប់ប្រាប់ខ្ញុំថា គេទាំងអស់គ្នាជាពួកអ្នករក្សាសេះរបស់ព្រះបាទមីហ៊ីស (Mihrage) ជាក្សត្រសោយរាជសម្បត្តិលើកោះនេះ ។ រាល់តែឆ្នាំក្នុងខែដដែល, ពួកយើងតែងនាំសេះញីមកបង្កាត់យកកូនពីសេះឈ្មោលមួយ ដែលតែងតែចេញពីបាតសមុទ្រមក ។ កាលណាធ្វើសន្ធិកិច្ចរួចហើយ សេះសមុទ្រមែងដេញខាំប៉ុនប៉ងនឹងស៊ីសេះញី, តែពួកយើងរត់ចេញទៅពីរូងនេះ ស្រែកបង្អើលសេះនោះឲ្យលោតចុះទៅក្នុងសមុទ្រវិញ ។ ឯកូនសេះឈ្មោលដែលសម្រាលពីមេសេះបង្កាត់នោះ សម្រាប់ប្រើជាព្រះទីនាំងពាជីរបស់ព្រះបាទមីហ៊ីស ហើយឲ្យឈ្មោះថាសេះសមុទ្រ ។ ពួកអ្នកទាំងនោះប្រាប់ខ្ញុំទៀតថា គេនឹងវិលត្រឡប់ទៅកាន់ទីក្រុងវិញ ក្នុងពេលព្រឹកស្អែក; បើប្រសិនជាខ្ញុំយឺតយូរតែមួយថ្ងៃទៀតមុខជានឹងស្លាប់មិនខាន ព្រោះទីក្រុងនៅឆ្ងាយណាស់ ទាំងស្រុកភូមិក៏គ្មាននៅជិតទីនោះដែរ បើគ្មានគេដឹកនាំបង្ហាញផ្លូវ នឹងរកទីភូមិមួយមិនឃើញឡើយ ។

ខ្ញុំរសាត់ទៅតាមរលកប្រឹងហែលទាំងយប់ទាំងថ្ងៃ ឥតសង្ឃឹមថានឹងបានរួចអំពីសេចក្ដីស្លាប់សោះ ស្រាប់តែមានរលក ១ ធំបោកបន្សាត់ខ្ញុំទៅប៉ះនឹងច្រាំងកោះ ១ ដែលមានច្រាំងខ្ពស់ពេកហើយលំបាកនឹងឡើងទៅដល់ទីខាងលើ បើប្រសិនជាគ្មានឫសឈើខ្លះ ដែលដុះឡើងសៀកសឹកនឹងថ្មតាមមាត់ច្រាំងនោះ ខ្ញុំប្រហែលជាឡើងទៅលើកោះនោះមិនរួចទេ ។ ខ្ញុំអស់កំលាំងហត់ហែលទន់ដៃទន់ជើង ដេកផ្ងៀកស្ពឹកស្ពន់លើផែនដី រហូតដល់ព្រឹកព្រាងថ្ងៃរះពេញពន្លឺ ។

ខ្ញុំមានសេចក្ដីស្រេកឃ្លានខ្លាំង ព្រោះអត់អាហារមកជាយូរថ្ងៃហើយ ខ្ញុំត្រេតត្រដររកទៅដកផ្លូវស្មៅណា ដែលល្មមបរិភោគជំនួសអាហារបាន, ខ្ញុំបានប្រទះអណ្ដូងទឹកសាបមួយ, លុះបានផឹកទឹកនោះរួចហើយទើបមានកំលាំងកំហែងគ្រាន់បើ, ខ្ញុំក៏ដើររុករកលើកោះនោះ ក្រែងលោបានជួបប្រទះនឹងមនុស្សណាមួយ ខ្ញុំបានចេញទៅកន្ទេលមួយធំ បានឃើញសេះញីមួយកំពុងឈរស៊ីស្មៅ ខ្ញុំក៏ដើរតម្រង់ចូលទៅជិតមានសេចក្ដីអរអរ ព្រោះមិនដឹងជាបានជួបប្រទះនឹងសេចក្ដីសុខទុក្ខយ៉ាងណា មេសេះនោះមានរូបពណ៌ស្អាតបាត ចងនឹងបង្គោលមួយ ។ ខ្ញុំកំពុងតែសង្កេតមើលសេះនោះ ស្រាប់តែឮសូរមាត់មនុស្សនិយាយគ្នាក្នុងរូងដី; លុះតមកមួយស្របក់ មនុស្សម្នាក់ចេញពីរូងដីដើរតម្រង់មករកខ្ញុំ ហើយបានសាកសួរដំណើររឿងហេតុរបស់ខ្ញុំសព្វគ្រប់ រួចហើយក៏ដឹកដៃខ្ញុំ

ដើរចូលទៅក្នុងដីនោះវិញ ។ ក្នុងទីនោះមានមនុស្សឯទៀតជាច្រើន អ្នកទាំងអស់នោះមានសេចក្ដីងឿងឆ្ងល់នឹងខ្ញុំណាស់ ដោយឃើញខ្ញុំនៅត្រមោចតែម្នាក់ឯងលើកោះនេះ ។ អ្នកខ្លះរៀបចំអាហារបន្តិចបន្តួចឲ្យខ្ញុំបរិភោគ, កាលបើបានកំលាំងពលំគ្រាន់បើហើយ ខ្ញុំក៏សាកសួរទៅអ្នកទាំងអស់នោះថា ដែលនាំគ្នាមកពួននៅក្នុងដីនេះ តើដើម្បីប្រយោជន៍អ្វី ? គេបាននិយាយរៀបរាប់ប្រាប់ខ្ញុំថា គេទាំងអស់គ្នាជាពួកអ្នកគង្វាលសេះរបស់ព្រះបាទមីហ្រាស់ (Mihrage) ជាក្សត្រសោយរាជសម្បត្តិលើកោះនេះ ។ រាល់តែឆ្នាំក្នុងខែដដែល, ពួកយើងតែងនាំសេះញីមកបង្កាត់យកកូនពីសេះឈ្មោលមួយ ដែលតែងតែចេញពីបាតសមុទ្រមក ។ កាលណាធ្វើសន្ធវកិច្ចរួចហើយ សេះសមុទ្ររមែងតែងតាំងប៉ុនប៉ងនឹងស៊ីសេះញី, តែពួកយើងរត់ចេញទៅពីរូងនេះ ស្រែកបន្លឺសេះនោះឲ្យលោតចុះទៅក្នុងសមុទ្រវិញ ។ ឯកូនសេះឈ្មោលដែលសម្រាលពីមេសេះបង្កាត់នោះ សម្រាប់ប្រើជាព្រះទីនាំងពាជីរបស់ព្រះបាទមីហ្រាស់ ហើយឲ្យឈ្មោះថាសេះសមុទ្រ ។ ពួកអ្នកទាំងនោះប្រាប់ខ្ញុំទៀតថា គេនឹងវិលត្រឡប់ទៅកាន់ទីក្រុងវិញ ក្នុងពេលព្រឹកស្អែក; បើប្រសិនជាខ្ញុំយឺតយូរតែមួយថ្ងៃទៀតមុខជានឹងស្លាប់មិនខាន ព្រោះទីក្រុងនៅឆ្ងាយណាស់ ទាំងស្រុកភូមិក៏គ្មាននៅជិតទីនោះដែរ បើគ្មានគេដឹកនាំបង្ហាញផ្លូវទេ នឹងរកទីភូមិមួយមិនឃើញឡើយ ។

ពួកនោះក៏ពុំតែនិយាយរៀបរាប់រឿងកំសត់ត្រង់ប្រាប់ខ្ញុំថា នៅនេះ ស្រាប់តែឃើញសេះសមុទ្រចេញពីសមុទ្រមក រកមេសេះញី ហើយក៏ធ្វើសន្និកិច្ចតាម ៗ រួចដេញខាំសេះញីនោះ ៗ ពួកគង្វាលសេះនាំគ្នាស្រែកចេញពីរូងដីមក ហើយស្រែកហោកញ្ជ្រៀវដេញបង្អើល ៗ សេះសមុទ្រក៏ផ្អើលរត់ហោះតម្រង់ទៅកន្ទាតសមុទ្រវិញទៅ ។

លុះដល់ព្រឹកស្អែកឡើង ពួកគង្វាលសេះនាំគ្នារៀបចំដំណើរទៅកាន់ទីក្រុងវិញ ដឹកនាំមេសេះទៅជាមួយផង ខ្ញុំក៏ទៅជាមួយនឹងគេដែរ កាលទៅដល់ហើយ គេនាំខ្ញុំទៅថ្វាយចំព្រះចៅមីក៏ស៍ ព្រះអង្គមានព្រះទ័យសោកយកក់ទាក់ ត្រាស់សួរដំណើរដើមទង ដែលខ្ញុំបានមកដល់នគររបស់ព្រះអង្គ ៗ កាលដែលខ្ញុំបានក្រាបទូលរ៉ាយរ៉ាប់សព្វគ្រប់ហើយ ព្រះអង្គមានព្រះទ័យមេត្តាករុណាដល់ខ្ញុំ ទ្រង់ត្រាស់ប្រើឲ្យគេយកគ្រឿងប្រដាប់ប្រដាសព្វគ្រប់មកប្រទានខ្ញុំ ដើម្បីប្រើប្រាស់តាមសេចក្ដីត្រូវការ ។

ដោយហេតុខ្លួនខ្ញុំធ្លាប់ជាអ្នកជំនួញ ទើបខ្ញុំរកបាយសេពគប់នឹងពួកឈ្មួញដូចគ្នា ខ្ញុំចូលដៃតែនឹងឈ្មួញណាដែលមកពីចម្ងាយដូចខ្ញុំ ដើម្បីនឹងសាកសួរដំណឹងពីក្រុងបាគដាទ ក្រែងលោមានអ្នកណាមួយមកពីក្រុងនោះ ហើយខ្ញុំនឹងត្រឡប់ទៅវិញដោយសារផង ៗ ទីក្រុងព្រះបាទមីក៏ស៍ ឋិតនៅក្បែរមាត់សមុទ្រ ហើយមានកំពង់ផែយ៉ាងស្អាត

សំពៅពីប្រទេសក្រៅចេញចូលបតជាច្រើនពល់ៗថ្ងៃ ។ ខ្ញុំបានសេព
គប់នឹងក្រុមអ្នកប្រាជ្ញប្រទេសឥណ្ឌាដែរ ខ្ញុំយកចិត្តទុកដាក់ស្តាប់អ្នក
ប្រាជ្ញប្រជុំនិយាយគ្នាជារឿយៗ ហើយខ្ញុំមិនដែលធ្វេសប្រហែសនឹងកិច្ច
ការ ដែលត្រូវទាប់ព្រះករុណាពល់ថ្ងៃនោះឡើយ ។ ដោយខ្ញុំជាអ្នក
ប្រៀតប្រៀតសួរពីកិច្ចការប្លែកផ្សេងៗ ដែលមាននៅក្នុងនគរជំរុះ
ខ្ញុំក៏បានដំណឹងថា នៅក្នុងសាគរទេក្ខរបស់ព្រះបាទមីរ៉ាសនេះ មាន
កោះមួយនៅឆ្ងាយដាច់ពីគេ ហៅថាកោះកសៀល ។ ក្នុងកោះនេះ
ពល់តែយប់គេតែងឮស្នូរសព្ទស្គរឡើងឃ្លោះ តែមិនដឹងជាឮមកពីទិស
ណាមក ហើយមិនដឹងជាអ្នកណាវាយ ពួកអ្នកសំពៅតែងនាំគ្នា
ជឿថាព្រះមួយព្រះអង្គព្រះនាម ដេកស៊ីយ៉ាល់ (Deggial) ឋិតនៅលើ
កោះនោះ, ខ្ញុំចង់ឃើញការចំឡែកអស្ចារ្យនោះឲ្យច្បាស់នឹងភ្នែកខ្ញុំ ទើបខ្ញុំ
ជិះសំពៅទៅជាមួយនឹងគេ ។ កាលទៅតាមផ្លូវ ខ្ញុំបានឃើញត្រី
១ បែប បណ្តោយខ្លួនប្រហែល ១០០ ឬ ២០០ ហត្ថ ត្រីនោះឥតមាន
ឡើងទាសអ្វីផល់ហើងទេ វាខ្លាចហើយណាស់ គ្រាន់តែឮស្នូរហើយវាយ
ឈើពាំហាលរះគបទៅឆ្ងាយ ។ មានត្រី ១ បែបទៀតមានក្បាលដូចជា
ក្បាលទំទុយ ។

កាលត្រឡប់មកដល់ក្រុងព្រះបាទមីរ៉ាសវិញ ពេលដែលខ្ញុំឈរ
នៅចាំកំពង់ផែ ស្រាប់តែមានសំពៅមួយចូលមកបតនៅទីនោះ

លុះបោះយុថ្ការួចស្រេចហើយ ទើបគេតាំងផ្ញូនទំនិញឡើងពីសំពៅ ពួកឈ្មួញជាម្ចាស់ទំនិញតាំងដឹកនាំទំនិញបញ្ចូលហាង ។ ខ្ញុំក្រឡេកមើលទៅឡាំងធំៗ ខ្លះស្រាប់តែបានឃើញឈ្មោះខ្ញុំបិទនៅលើឡាំងនោះ, កាលបើបានពិនិត្យដឹងច្បាស់ជាឡាំងទំនិញរបស់ខ្ញុំហើយ. ខ្ញុំក៏សង្កេតមើលនាយកម្មែតឲ្យជាក់ច្បាស់ទៀត ក៏បានស្គាល់ថាជានាយកម្មែតសំពៅដែលខ្ញុំជិះចេញពីក្រុងបាល់សូរ៉ាមកនោះឯង. ខ្ញុំដើរទៅជិតនាយកម្មែតសំពៅនោះហើយសួរថា ឈ្មួញជាម្ចាស់ឡាំងទំនិញនេះគេឈ្មោះអ្វី ? ណាយកម្មែតសំពៅឆ្លើយថា ឈ្មោះសិន្ទបាដ, គាត់បានតាំងនិយាយរឿងរ៉ាវដែលយកត្រីបាឡែនថាជាកោះ ហើយបានបើកសំពៅចេញចោលសិន្ទបាដ ដោយគិតស្មានថាសិន្ទបាដស្លាប់ក្នុងទឹកទៅហើយ ។ នាយកម្មែតសំពៅប្រាប់ថា ខ្ញុំនឹងលក់ទំនិញនេះឲ្យអស់ ហើយយកលុយគាត់ទៅប្រគល់ឲ្យគ្រួសាររបស់ឈ្មួញសិន្ទបាដ ។ កាលបានឮជាក់ច្បាស់ថាជាទំនិញរបស់ខ្លួនដូច្នេះហើយ សិន្ទបាដឆ្លើយប្រាប់នាយកម្មែតសំពៅថាគឺខ្លួនខ្ញុំនេះឯងហើយដែលឈ្មោះសិន្ទបាដ ។ នាយកម្មែតសំពៅក៏ស្រឡាំងកាំងហើយនិយាយថា "ពុទ្ធោអើយ! អ្នកឯងមានកំស្ដា៖ត្រង់ណា? មនុស្សក្នុងលោកសព្វថ្ងៃនេះរកជឿមិនបានទេ សិន្ទបាដស្លាប់បាត់ទៅហើយ ខ្ញុំបានឃើញជាក់ច្បាស់នឹងភ្នែកខ្ញុំ ។ អ្នកឯងពេញជាហ៊ានមែន ខ្ញុំមើលមុខអ្នកឯងគួរជាមនុស្សស្លូតត្រង់ល្អ មិនគួរនឹងហ៊ានមក

ក៏យើងបំភាន់មនុស្សយកទ្រព្យគេយ៉ាងនេះហោះ” ។ ខ្ញុំប្រឹងនិយាយលួងលោមនាយកម្រួតសំពៅឲ្យទ្រាំចាំស្ដាប់ ខ្ញុំនឹងពណ៌នាអំពីដំណើរដើមបមដែលខ្ញុំបានរួចអំពីសេចក្ដីស្លាប់នោះ នាយកម្រួតសំពៅក៏ព្រមព្រៀងតាម ។ ខ្ញុំចាប់ផ្ដើមអធិប្បាយសព្វគ្រប់តាមដំណើរតាំងអំពីដំបូងដែលហែលទឹកទៅជាប់នឹងកោះព្រះបាទមីក៍ស៍ រហូតតរៀងមកដល់ជួបនឹងនាយកម្រួតសំពៅនេះ ។

នាយកម្រួតសំពៅ មានសេចក្ដីរំភើបនឹងរឿងដែលខ្ញុំអធិប្បាយមកនោះ ហើយជឿជាក់ថាខ្ញុំឈ្មោះស៊ិនបាដមែន ពួកកម្មករសំពៅខ្លះបានមើលខ្ញុំស្គាល់ក៏រត់មកជួបខ្ញុំ មានសេចក្ដីត្រេកអរណាស់ដោយបានឃើញខ្ញុំរស់ជីវិត ។ នាយកម្រួតសំពៅចាប់ដៃខ្ញុំហើយនិយាយថា “អ្នកមានសំណាងធំណាស់ អ្នកមានគ្រោះថ្នាក់ មិនគួរនឹងរស់រួចជីវិតបានទេ, ខ្ញុំមានសេចក្ដីត្រេកអររកអ្វីមកប្រៀបពុំបាន, អញ្ជើញអ្នកទទួលយកទ្រព្យសម្បត្តិអ្នកចុះ” ។ ខ្ញុំអរគុណទៅនាយកម្រួតសំពៅ និយាយសរសើរអំពីសេចក្ដីទៀងត្រង់របស់គាត់ ហើយខ្ញុំបានជូនទំនិញខ្លះទៅគាត់ដើម្បីតបស្នងសងគុណគាត់ តែគាត់មិនព្រមទទួលយក ។

ខ្ញុំជ្រើសរើសស្រម៉ាំងវត្ថុណា ដែលល្អហើយយ៉ាងថ្លៃថ្នូរយកទៅថ្វាយតបស្នងសងព្រះគុណព្រះបាទមីក៍ស៍ ។ ដោយព្រះអង្គទ្រង់បានជ្រាបថាខ្ញុំជាបុរសកំសត់ទុគ៌ត ព្រះអង្គទ្រង់ទទួល ក៏សាកសួរខ្ញុំអំពី

ដំណើរដើមទង ដែលខ្ញុំបានវត្ថុដ៏មានជ័យនេះមកថ្វាយព្រះអង្គ ខ្ញុំក្រាបទូលសព្វគ្រប់តាមដំណើរដែលបានចួបប្រទះនាយតម្រួតសំពៅ ព្រះអង្គទ្រង់មេត្តាប្រោសប្រណី សំដែងទឹកព្រះទ័យរីករាយសប្បាយសរសើរសំណាងរបស់ខ្ញុំ ព្រះអង្គទ្រង់សួរខ្ញុំ ហើយទ្រង់មេត្តាព្រះរាជទានទ្រព្យសម្បត្តិដល់ខ្ញុំជាច្រើន ។

ក្រោយពីនោះមក ខ្ញុំក្រាបថ្វាយបង្គំលាព្រះអង្គ ចុះសំពៅដដែលត្រឡប់ទៅស្រុកវិញ ។ ប៉ុន្តែរត្នជាតិអម្បាលម៉ាន ដែលនាយតម្រួតសំពៅប្រគល់ឲ្យខ្ញុំនោះ ខ្ញុំយកទៅប្តូរនឹងវត្ថុឯទៀតដែលយកទៅលក់ស្រុកខ្ញុំបានថ្លៃច្រើន ដូចជាឈើខ្លឹមក្រពើ, ការបូរ, ខ្លឹមហាល, ដែកគោល, ម្រេច... ។ សំពៅបានបកបរទៅតាមកោះជាច្រើនដែលប្រទះតាមផ្លូវ រួចបានដល់មកក្រុងបាស់សូរ៉ា ខ្ញុំលក់ដូរទំនិញរួចស្រេច ឃើញបានចំណេញសោហ៊ុយចំនួនមួយសែនកហាបណៈ ។ ក្រុមញាតិខ្ញុំបានចុះមកទទួលខ្ញុំ ក៏ទទួលអបអរដោយសោះស្ត្រែត, ខ្ញុំនាំក្រុមញាតិខ្ញុំទៅក្រុងបាគ្ដាទ ហើយបានទិញខ្ញុំកំដរប្រុសស្រី, ផ្ទះសម្បែង, ដីធ្លី ដោយបំរុងនឹងនៅរកស៊ីឲ្យសប្បាយដើម្បីភ្លេចសេចក្ដីនឿយហត់ ដែលខ្ញុំបានទ្រាំទ្រមកហើយនោះឯង ៕

សិនបាតបញ្ចប់រឿងទី ១ ត្រឹមនេះ ហើយក៏បង្គាប់ពួកក្មេងឲ្យចាប់ភ្លេងឡើង, សៀងភោជនាហារក្សាន្តសប្បាយ លុះត្រាតែដល់ពេល

កក្រើ ៗ មុននឹងបែកខ្ញែកគ្នា សេដ្ឋីបានយកប្រាក់ចំនួន ១០០ កហាប-ណៈមកប្រគល់ឲ្យហិន្ទុបាជ ប្រាប់ឲ្យត្រឡប់មកកាន់ផ្ទះលោកវិញក្នុងថ្ងៃស្អែក ដើម្បីនឹងស្តាប់រឿងដើរសមុទ្រលើកទីពីរតទៅទៀត ។ បុរសស៊ីឈ្នួលថយចេញទៅ ដោយសេចក្តីត្រេកអរទៀបទៀងនឹងការកំសាន្តរបស់សេដ្ឋី ហើយនឹងចំនួនប្រាក់ដែលបានទទួលហើយនោះឯង, លុះបានទៅដល់ផ្ទះកាលណា ទើបហិន្ទុបាជបានអធិប្បាយរឿងខ្លួនដោយលៃបទាយ ប្រាប់ប្រពន្ធកូនទាំងអស់ ។

ថ្ងៃស្អែកឡើង ទុគ្គតបុរសហិន្ទុបាជស្លៀកពាក់ប្រញាប់ប្រញាល់ហើយទៅកាន់ផ្ទះលោកសិន្ទុបាជ ។ ក៏បានទទួលរាក់ទាក់ដោយសេចក្តីស្មោះសរ ។ កាលពួកភ្ញៀវមកជួបជុំគ្នាអស់ហើយ លោកឲ្យគេតាក់តែងជប់លៀងភោជនាហារដូចថ្ងៃមុន ។ លុះលៀងភ្ញៀវរួចហើយទើបសិន្ទុបាជចាប់ផ្តើមនិយាយរឿងដើរសមុទ្រទីពីរឲ្យអ្នកទាំងនោះស្តាប់ដូចសេចក្តីតទៅនេះ ។

(មានត)

# ព្រះរាជប្រវត្តិ

## ព្រះបាទសម្តេចព្រះជ័យជេដ្ឋា (ព្រះអង្គសូរ)

ឃុនទិព្វមន្ត្រី ញ៉ុក-ថែម រៀបរៀង

(តមក)

---

ថ្ងៃ ៥ កើតខែពិសាខឆ្នាំកុរសប្តស័ក ព.ស. ២២៣៩ វេលាព្រឹកជាពេលបានឫក្សវរមង្គល ព្រះឧទ័យរាជា (ព្រះអង្គឈន់) ព្រះជន្ម ២៣ វស្សា ព្រះរាជបុត្រសម្តេចព្រះកែវហ្វា (ព្រះអង្គជី) ស្តេចឡើងសោយរាជសម្បត្តិតពីសម្តេចព្រះបិតុលា ៗ ទ្រង់ដឹកព្រះហស្តាឡើងបុស្បក ហើយទ្រង់ព្រះរាជតាំងទុករាជាភិសេក ព្រះរាជគ្រូបុរោហិតសូត្រស្តីថ្វាយជ័យមង្គលតាមប្រវេណី រួចស្តេចទ្រង់គ្រឿងប្រដាប់សម្រាប់រាជ្យ ទ្រង់ព្រះនាមព្រះបាទសម្តេចព្រះរាជឱង្ការព្រះនារាយណ៍រាមាធិបតី ព្រះឧទ័យរាជាបរមបពិត្រ ៗ ទ្រង់តាំងព្រះសុជាតាវតីជាសម្តេចព្រះអគ្គមហេសី ស្តេចគង់នៅព្រះរាជវាំងស្រះកែវឧត្តពុជ័យ ៗ

## ព្រះជ័យជេដ្ឋាស្តេចទ្រង់ព្រះផ្នួសជាគំរប់ ២ ដងបាន ១ វស្សា[1]

កន្លងឆ្នាំដែលនេះ ព្រះបាទសម្តេចព្រះជ័យជេដ្ឋាបរមបពិត្រ ស្តេចចេញបព្វជ្ជាជាភិក្ខុ នៅវត្តព្រៃពួន កន្លែងគ្រសាំងទន់ស្តាំ ដែលទ្រង់ឲ្យកសាងឡើងនោះបាន ១ វស្សា លុះចេញវស្សាស្តេចចាក

---

១ ច្បាប់សាស្ត្រាស្ទើករីតគឺងច្បាប់ពោះពុម្ពជាភាសាថៃ ថាព្រះបាទសម្តេចព្រះជ័យជេដ្ឋាបរមសុរិន្ទ្រស្តេចចេញទៅទ្រង់ព្រះផ្នួសជាភិក្ខុបានតែ ៥ ថ្ងៃ ៗ

សំរិទ្ធបទ ហើយស្តេចទ្រង់ប្រថាប់នៅព្រះពន្លាកំពុលលោកជាភាស្នេហ៍ ក្តៅព្រាត្រូននោះយូរទៅ មានទីដំណែលនៅទីនោះប្រែឥតទ្ធី គឺទីទ្រង់ព្រះទីនាំងគង់ទ្រូ ទីកេងសម្រាប់ចងព្រះទីនាំងហត្ថី អន្លង់លានព្រះទីនាំងគង់ទ្រូ ហៅថាអន្លង់សំបូណ៌មាន ក្រោយមកគេហៅថាសំបុរមាន ស្តេចចិញ្ចឹមរមាំងស ១ នៅទីតាំងត្បូង បានជាជាប់ហៅថាភូមិរមាំងស លុះយូរមកគេហៅថាភូមិមោំងទៅវិញ ។

ទ្រង់ព្រះចិន្តាថា ក្តៅព្រាត្រូននេះនៅឆ្ងាយពីស្ទឹងណាស់ ទឹកចូលព្រះទីនាំងនាក់ពុំដល់ក្តៅ ក៏ទ្រង់ត្រាស់ឲ្យភ្នាក់ងារមន្ត្រីគណ្ឌកស្តេចជីកព្រែក ឲ្យខប់ស្ទឹងខាងលើ ឲ្យលើកថ្នល់ទប់មាត់ព្រែកខាងត្បូង ខាងកើតក្តៅព្រាត្រូនបទឲ្យជីកជាស្ទឹង ត្រង់ទៅចុង្គកកាត់ជម្រង់ទៅកំពង់ឈើប្រាក់ ដើម្បីឲ្យទឹកហូរហោយមកជាប់ជាទិច្ចូ ទឹកចូលព្រះទីនាំងនាក់មកសានព្រះកម្សុសបក្តៅព្រាត្រូនបានដោយងាយ ។ វេលានោះមន្ត្រីតូចម្នាក់ទទួលមុខងារត្រួតត្រាខាងទំសន្លៀសោធក្ត មន្ត្រីធំបង្គាប់ថា បំជីកឲ្យហើយក្នុង ៣ ថ្ងៃ បើមិនហើយនឹងយកទោសដល់ជីវិត មន្ត្រីនោះព្រួកស្តេចឲ្យជីកមិនហើយតាមកំណត់ ក៏យកណាស់តែទៅចងកសម្លាប់ខ្លួនក្នុងព្រែខាងលើង ។ ទីដែលជីកពុំទាន់ហើយហៅថាភូមិសល់ជី ។ ព្រែកដែលមន្ត្រីនោះចងក ជាប់ហៅថាព្រែកចងករបៀងមក ព្រែកជីកនៅមាត់ស្ទឹងហៅថាភូមិព្រែក ។ កន្លែងដែលជីកឲ្យទៅជាស្ទឹងនោះជាប់ហៅថា

ជំនឹក ការដែលធ្វើនោះក៏ឈប់តាំងពីនោះមក គង់នៅទីដំណែភាលលុះ ដល់សព្វថ្ងៃ ។

៦ព្រះបាទសម្តេចព្រះនារាយណ៍រាមាធិបតី សោយរាជសម្បត្តិបាន ១០ [១] ឆ្នាំ ទ្រង់ព្រះអាពាធព្រះវិសភេទជាទម្ងន់ ពេទ្យប្រកបថ្នាំ ថ្វាយពុំត្រូវ ។

លុះដល់ថ្ងៃ ៤ កើតខែមាឃ ឆ្នាំកុរសប្តស័ក (ព.ស. ២២៣៩) ទ្រង់សោយព្រះទិវង្គតទៅ ទើបសេនាបតីមន្ត្រីរៀបដំកល់ព្រះបរមសព ក្នុងព្រះមហាមន្ទីរតាមទំនៀម ហើយនាំគ្នាទៅក្រាបទូលព្រះបាទសម្តេច ព្រះជ័យជេស្ឋាឲ្យទ្រង់ជ្រាប ហើយក្រាបបង្គំទូលទ្រង់ឲ្យឡើងគ្រងរាជ្យ វិញ ទ្រង់ក៏ទទួល ទើបស្តេចព្រះរាជដំណើរចេញពីព្រះពន្លាក្តៅព្រៃពួន ទៅកាន់ក្រុងឧត្តុង្គពុជ័យ ។

ថ្ងៃក្រោយមក ទ្រង់បង្គាប់មន្ត្រីឲ្យសង់ព្រះមេរុខាងកណ្តាលវាំង ស្រេចឲ្យហែព្រះបរមសពទៅដំកល់ក្នុងព្រះមេរុ ៧ ថ្ងៃ ទ្រង់បំពេញព្រះរាជកុសលគល់វេលា រួចព្រះរាជទានព្រះភ្លើង ហែព្រះបរមអដ្ឋិដំកល់ក្នុងកោដ្ឋមាសហែទៅបញ្ចុះក្នុងព្រះចេតិយទន្លឹម នៅភ្នំព្រះរាជទ្រព្យ ។

---

• ប្រវត្តិក្សត្រស្រុកខ្មែរនឹងច្បាប់ព្រះពុទ្ធសាសនាសាថៃថា ព្រះនារាយណ៍រាមាធិបតីស្តេចគ្រងរាជសម្បត្តិបាន ២ វស្សា គឺឡើងគ្រងរាជ្យក្នុងឆ្នាំកុរឯកស័កដល់មកឆ្នាំជូតអដ្ឋស័កព្រះជន្ម ៤៤ វស្សា ទើបស្តេចសោយទិវង្គត ។ មហាសករាជ ១៦១៩ ឆ្នាំជូតឯកស័កនោះ សម្តេចព្រះជ័យជេស្ឋាបរមសុរិយោព្រាធិរាជទ្រង់ទទួលរាជសម្បត្តិមកវិញ ។

## ព្រះជ័យជេដ្ឋាស្ដេចឡើងគ្រងរាជសម្បត្តិជាគំរប់ ២ ដង

ព. ស. ២២៤០ ម. ស. ១៦១៨ ច. ស. ១០៥៨, ក្នុងថ្ងៃច័ន្ទ ៦ កើត ខែពិសាខ ឆ្នាំជូត អដ្ឋស័ក . វេលាព្រឹកបានឫក្សវរមង្គលប្រពៃមាន សោភ័ណជ័យ ។

ទើបព្រះបាទសម្ដេចព្រះជ័យជេដ្ឋា ព្រះជន្ម ៣៧ វស្សា ស្ដេចឡើងសោយរាជសម្បត្តិជាគំរប់ពីរលើក: តពីព្រះបាទសម្ដេចព្រះឧទ័យរាជាធិបតី . ជាព្រះរាជភាគិនេយ្យមក ទ្រង់តាំងសម្ដេចព្រះកតៃ ជាទីព្រះអគ្គមហេសីដូចពីដើម ស្ដេចគង់ក្នុងព្រះបរមរាជវាំង ស្រះកែវក្រុងឧត្តុង្គជ័យ ។

ក្នុងឆ្នាំជាវេលានេះ ឧកញ៉ាអញ្ញាសង្គ្រាម (ពៅ) ចៅហ្វាយស្រុកខែត្រត្រើយ ៣ បានចាប់សនាធ ១ សម្បុរខ្មៅថ្មី នាំមកថ្វាយទ្រង់មានអំណរណាស់ ទ្រង់ប្រោសព្រះរាជទានរង្វាន់ឧកញ៉ាអញ្ញាសង្គ្រាម (ពៅ) និងជាវេលាដាក់បានភាស៊ីសមគួរ ។

ថ្ងៃក្រោយមក ទ្រង់ត្រាស់បង្គាប់មន្ត្រីរាជការឲ្យធ្វើពេនប្រក់ស្បូវភ្លាំង សម្រាប់ទ្រង់ដំរី ហើយត្រាស់ឲ្យរៀបហែសម្ភោធ ៣ ថ្ងៃចូលពេន ទ្រង់តាំងនាមជានាង ស្រីមង្គលហត្ថី[១] ។

---

១- Cao-Men-Ky-Luoc ថាឆ្នាំគមក (1696) សា-យី-ទ្រី-ស្វ-ថា-ស្វ ឡើងគ្រងរាជបល្ល័ង្ក ទ្រង់បានដំរីសញ្ញ ១ ។

ព្រះបាទសម្តេចព្រះជ័យជេដ្ឋា ទ្រង់ប្រកបដោយទសពិធរាជធម៌ ព្រះពុទ្ធសាសនាក៏ចំរើនរុងរឿងល្អ ។

## ទ្រង់បាត់មន្ត្រីឲ្យទៅទទួលព្រះអង្គអិមនៅស្រុកយួន (១)

ថ្ងៃមួយ ស្តេចទ្រង់នឹកព្រះទ័យថា អ្នកអង្គអិម ជាបុត្រសម្តេចព្រះថាមរាជា (ព្រះអង្គនន់) ដែលខ្លាត់ព្រាត់ទៅនៅស្រុកយួនដោយខាងខ្លួន ព្រោះព្រះបិតាជាសត្រូវនឹងយើង អ្នកអង្គអិមនោះក៏ជាការនៃ-យោបល់របស់យើង ហើយនៅក្មេងណាស់ ទ្រង់ប្រកាន់ទោសពុំបាន តែខុសទំនៀមទំនៀមក្សត្រ បើសម្លាប់ញាតិកុំឲ្យកូន ខ្លួនយើងក៏ជាក្សត្រធំប្រកបដោយបារមីគុណប្បៈតាមពុទ្ធវចនៈ គួរយើងឲ្យទៅនាំយកអ្នកអង្គអិមមកវិញទើបគួរ ហើយស្តេចប្រជុំសេនាបតីមន្ត្រីទាំងពួង នៅចំពោះព្រះភក្ត្រទ្រង់ត្រាស់ប្រាប់ថា យើងនឹងបាត់មន្ត្រីឲ្យទៅសុំអ្នកអង្គអិម ពីស្តេចយួនវិញតើគួរឬពុំគួរ ។ សេនាបតីមន្ត្រីទាំងនោះក្រាបបង្គំទូលថា ដែលទ្រង់ព្រះតម្រិះនឹងប្រមូលព្រះរាជវង្សានុវង្ស មិនឲ្យខ្លាតខ្លាត់ទៅនៅ

---

១ Cao - Men - Ky - Luoc ថា ស៊ះ-យ៉ី-ទ្រី-ស៊ូ-ឋា-សូ ទ្រង់បាត់ឲ្យអញ្ជើញព្រះរាជ-នេយ្យ ព្រះអង្គឯមដែលមកនៅក្នុងប្រទេសយើង (អង្គឯមនេះមានព្រះជន្ម ១៦ វស្សា) ។ ក្នុងឆ្នាំគមរបសកកដយ៉ាញ-សូ (1697) ទ្រង់បានអភិសេកសបវស ហ្វេ-ឌិប-ភក-ពរស់ ធុបា (សម្តេចមហាក្សត្រី) ជាព្រះបុត្រីរបស់ ទាំងពីរបៀបចំផ្សាមរសបងប្អូនជីដូនមួយ នឹងបងប្អូនជីដូនមួយ ដែលជាដំណវង្សចុះមកអំពីជីតាជាមួយគ្នា ។

ដោយនគរនោះប្រពៃណាស់ នានាប្រទេសទីនសរសើរព្រះបារមី ។

១ ទៀតព្រះអង្គអឹម នោះជាព្រះរាជបុត្រាសម្តេចព្រះបទុមរាជា (ព្រះគង្គទន្ធ) ដែលជាសត្រូវនឹងព្រះអង្គ បើទ្រង់យកមកចិញ្ចឹមបំរុងនឹងមានព្រះទ័យស្មោះត្រង់ ដែលឹងចង់ទុកសទីស្អួនថ្កល់ព្រះបាទតទៅ ។

លុះទ្រង់ប្រឹក្សាព្រមព្រៀងគ្នាស្រេច ស្តេចកាត់បង្គាប់ព្រះសុនេ-ហេហារ (មាស) ឲ្យតែងព្រះរាជសារទៅដល់ស្តេចយួនមានសេចក្តីថា:

ព្រះរាជសារបវរមង្គលផុលពីព្រះរាជហឫទ័យ នៃព្រះបាទសម្តេចព្រះជ័យចេស្តាពខាងសូរមេសុរិន្ទ្របរមបពិត្រ ព្រះចៅក្រុងកម្ពុជាធិបតី បំរើងថ្វីព្រះរាជមេត្រីមកព្រះចៅក្រុងអណ្ណាម, សូមទ្រង់ជ្រាប ។

ដ្បិតខ្ញុំព្រះអង្គជ្រាបដំណឹងថា អ្នកអង្គ (អឹម) ជាភាគិនេយ្យរបស់ខ្ញុំ បានចូលមកពឹងព្រះពោធិសម្ភារព្រះបារមីព្រះអង្គ ដោយព្រះរាជបិតាទីវង្គតទៅ ឥឡូវខ្ញុំប្រើឲ្យកញ្ញាទេពវង្ស (អ៊ុង) ១ កញ្ញាស្រេនជ័យ (ឡុង) ជារាជទូតឲ្យនាំក្រមួន ១០ ហាប គ្រកោ ២០ ហាប ភ្លុកដំរី ៤ ក្បាល រង ១០ ហាប ម្រ័ក្សណ៍ ៥០០ ក្អម ជារាជបណ្ណាការមកថ្វាយដោយថ្វីព្រះរាជមេត្រី ហើយសូមអ្នកអង្គ (អឹម) ឲ្យចូលទៅក្រុងកម្ពុជាវិញ ទីនបានជួបជុំព្រះរាជវង្សានុវង្ស ខ្ញុំនឹងចិញ្ចឹមបំរុងដូចជាបុត្រាបង្កើត ឥឡូវក្រុងកម្ពុជាធិបតីក៏ចំរើនឧឡារ សូមព្រះចៅក្រុងអណ្ណាមទទួលព្រមព្រៀងដោយថ្វីព្រះរាជមេត្រី ។

ទើបត្រាស់ប្រើឲ្យឧកញ៉ាទេពវដ្ឋន (អ៊ុង) ឧកញ៉ាស្រែនជ័យ (ឡុង) ព្រមដោយមន្ត្រី ១០ នាក់ និងរាស្ត្រចំណុះខ្លួន ១០០ នាក់ ឲ្យអញ្ជើញព្រះរាជសារនិងបណ្ណាការចុះទៅស្រុកយួន ។ ឧកញ៉ាទាំងពីរក៏ថ្វាយបង្គំលា នាំខ្ញុំរាជការចុះទូកចេញទៅស្រុកយួន ដល់ហើយឲ្យសេនាបតីក្រាបទូលស្តេចយួនតាមដំណើររឿងគ្រប់ប្រការ ។

ស្តេចយួនទ្រង់ជ្រាបទ្រង់ប្រឹក្សានឹងសេនាបតីមន្ត្រីទាំងពួងថា រឿងនេះព្រះចៅក្រុងកម្ពុជាធិបតី ប្រើរាជទូតឲ្យនាំព្រះរាជសារមកសុំអ្នកអង្គ (អីម) ទៅនគរវិញ តើអ្នកទាំងពួងយល់ដូចម្តេច ? សេនាបតីមន្ត្រីទាំងនោះក្រាបទូលថា រឿងនេះយើងព្រមឲ្យទៅក៏មិនបានមិនព្រមឲ្យទៅក៏មិនបាន ត្រូវសួរចិត្តអ្នកអង្គ (អីម) មើលសិន ។ បើព្រមទៅក៏តាមចិត្ត បើមិនព្រមទៅ ស្រេចចិត្តនៅនឹងយើងក៏បាន និងបង្ខំចិត្តគេពុំគួរ ។

ឯរាជទូតខ្មែរក៏នាំគ្នាទៅគាល់ព្រះអង្គ (អីម) ហើយទូលថ្វាយសេចក្តីគ្រប់ប្រការថា សម្តេចព្រះរាជបិតុលាព្រះអង្គនេះ ទ.ន ព្រះទ័យមេត្តាករុណាព្រះរាជវង្សានុវង្ស នាហ្មឺនសព្វមុខមន្ត្រីធំបណ្តារាស្ត្រព្រៃពល ។ ១ ទៀតទ្រង់មានព្រះដំកស់ថា និងព្រះរាជទានព្រះរាជពិតាជាព្រះរាជ-ទេពីព្រះអង្គផង បើទ្រង់មានព្រះទ័យសុចរិតស្មោះត្រង់ ស្តេចនឹងបំរើររាជសម្បត្តិព្រះរាជទាន សូមឲ្យទ្រង់យាងទៅក្រុងកម្ពុជាវិញចុះ ទូលព្រះ

បង្គំនឹងសូមពឹងព្រះបារមីតទៅ ៗ ១ទៀត បើទ្រង់ចង់ធ្វើសង្គ្រាមនឹងក្រុងកម្ពុជា សូមទ្រង់ព្រះចិន្តាឲ្យល្អិត ដ្បិតក្រុងកម្ពុជា គ្រានេះចំរើន រុងរឿងមាំមួនណាស់ ៗ

ព្រះអង្គ (អឹម) បានទ្រង់ស្ដាប់ ទ្រង់មានព្រះអំណរគតសទ្ធិៈសង្ស័យ ព្រោះឧកញ៉ាទេពវង្ស (អ៊ុង) ជាខ្ញុំរាជការចាស់ពីព្រះបទុម-រាជាព្រះវរបិតា ទើបទ្រង់មានព្រះបន្ទូលថា បើពិតដូចអ្នកនិយាយមែនខ្ញុំព្រមទៅ តែកងតែស្ដេចយួនមិនបើកឲ្យទៅ ចិត្តខ្ញុំមិនចង់ច្បាំងនោះ ដោយគិតឃើញថា ព្រះវរបិតាធ្វើសង្គ្រាមមក កស្ដែងជាក្នុងព្រះនគរអន្តរាយអស់ច្រើន បើខ្ញុំនៅតែគិតធ្វើសង្គ្រាមទៀត នឹងលំបាកផលចណ្ដាកស្ដែជាអនេក ៗ កាលខ្ញុំមកស្រុកយួន ព្រោះពុំទាន់ដឹងព្រះទ័យសម្ដេចព្រះបិតុលា ឲ្យដឹងពិតៈបាយគួរត្រឡប់ទៅស្រុកវិញ ៗ

ឯស្ដេចយួនលុះទ្រង់ប្រឹក្សារួចស្រេច ស្ដេចត្រាស់បង្គាប់សេនាបតីឲ្យនាំពួកខ្មែរចូលគាល់ សេនាបតីយួនក៏នាំឧកញ៉ាទេពវង្ស (អ៊ុង) និងឧកញ៉ាស្រែនជ័យ (ឡុង) ចូលគាល់ ៗ ឧកញ៉ាទាំងពីរក៏ថ្វាយព្រះរាជសារនិងរាជបណ្ណាការ ស្ដេចយួនទ្រង់ទទួលហើយត្រាស់ឲ្យថែព្រះរាជសារប្រាយ ទ្រង់ជ្រាបហើយមានព្រះបន្ទូលថា ការដែលព្រះចៅក្រុងកម្ពុជាប្រើអ្នកមកសុំអ្នកអង្គ (អឹម) ទៅវិញ ដោយហេតុព្រះរាជមេត្រីនេះ ចាំយើងសួរបញ្ជាក់អ្នកអង្គ (អឹម) សិន បើព្រមទៅយើងក៏មិនឃាត់

រួចត្រាស់ឲ្យហៅព្រះអង្គ (អឹម) ចូលគាល់ ទ្រង់សួរថា ឥឡូវព្រះចៅក្រុងកម្ពុជាឲ្យមកសុំកូយត្រឡប់ទៅព្រះនគរវិញ កូយព្រមទៅឬដូចម្ដេច ។ ចិត្តមាមិនចង់ឲ្យកូយទៅទេ តាំងចិត្តថានឹងជួយគិតយករាជសម្បត្តិក្រុងនគរក្រុងកម្ពុជាថ្វាយកូយឲ្យបាន ។ ១ ទៀតមាយល់ថា ព្រះចៅក្រុងកម្ពុជាអង្គនេះមានសតិបញ្ញាណាស់ មាក្រែងជាឧបាយបញ្ឆោតយកកូយទៅធ្វើទុក្ខទោស រឿងនេះបូកូយគិតឲ្យល្អិតផងចុះ ។ ព្រះអង្គ (អឹម) បានសណ្ដាប់ក៏ទ្រង់យល់ថា ស្ដេចយួននេះនិយាយបញ្ឆោតនឹងយកក្រុងកម្ពុជាជាចំណុះ បើខ្ញុំមិនព្រមទៅទេ មុខជានឹងកើតរវល់ដោយស្ដេចយួនអង្គនេះទៀតពុំខាន ព្រះអង្គ (អឹម) ក៏ទូលទៅស្ដេចយួនថា ដែលទូលបង្គំជាខ្ញុំពួលមកពឹងព្រះបរមពោធិសម្ភារ ទ្រង់ព្រះមេត្តាទំនុកបម្រុងបានសេចក្ដីសុខរៀងមកនេះ ទុកជាព្រះគុណធំបំផុត ការដែលគិតធ្វើសង្គ្រាមទៀតនោះ ទំនងលំបាកវេទនាដល់សេនាទាហាននឹងបណ្ដារាស្ត្រ ហើយនឹងមានពាក្យគរហានិន្ទាដល់នានាប្រទេសផង សេចក្ដីនេះស្រេចតែទ្រង់ព្រះមេត្តាប្រោស ។

ព្រះចៅក្រុងអណ្ណាមទ្រង់ព្រះសណ្ដាប់ទ្រង់ជ្រាបថា ព្រះអង្គ (អឹម) ចង់ត្រឡប់ទៅនគរវិញ ក៏ទាល់ទើបត្រាស់ថា បើកូយចង់ទៅនគរវិញ ក៏តាមចិត្តចុះ ។ ព្រះអង្គ (អឹម) នឹងឧកញ៉ាទាំងពីរក៏ថ្វាយបង្គំថយចេញមកវិញ ។ ក្រោយនោះ ស្ដេចយួនទ្រង់ប្រឹក្សានឹងសេនាបតីថា ឥឡូវ

ហើយនិស្សអ្នកអគ្គ (អ៊ឹម) ។ មិនព្រមទៅទេ អ្នកទាំងឡាយយល់ដូចម្ដេច ។ ១ ទៀតយើងឃាត់ទុកមិនឲ្យទៅក៏បាន ប៉ុន្តែក្រែងនានាប្រទេសគេហាមិន្ទា ដល់យើងថាមិនប្រកបដោយយុត្តិធម៌ ។ នាហ្មឺនសព្វមុខមន្ត្រីទូលថា ស្រេចតាមចិត្តគេចុះ ហើយគួរទ្រង់ព្រះរាជទានពល ៥០០ ជាចំណងព្រះហស្តទៅផង បើទៅមុខក្រុងកម្ពុជាកើតសង្គ្រាមនឹងយើងទៀត ពលទាំងនោះនឹងគិតការយកក្រុងកម្ពុជាឲ្យបាន ស្ដេចយួនក៏ទ្រង់យល់ព្រម ។ ទើបទ្រង់ចាត់ពលយួន ៥០០ ជាចំណងព្រះហស្ត ទ្រង់ព្រះបណ្ដាំសព្វគ្រប់ ទ្រង់ចាត់មន្ត្រីយួនឲ្យរៀបចំទូកហោជូនតាមសមគួរ ហើយត្រាស់ឲ្យចាត់ត្រៃ ១០០ កី ជាតី ២០០ ដាប់ សំពត់អាល្បាះសរលើប ៥០០ ដាប់ ត្រៃឡាញ់ហ្មត់ឈើធំ ១០០ កី ជារាជបណ្ណាការថ្វាយតបមកវិញ ។

ទើបត្រាស់ឲ្យរាជទូតខ្មែរទូលលា ទ្រង់ព្រះរាជទានរង្វាន់តាមសមគួរ ហើយស្ដេចយួនប្រគល់ព្រះអគ្គ (អ៊ឹម) នឹងរាជបណ្ណាការឲ្យរាជទូតខ្មែរ ទ្រង់ព្រះបណ្ដាំថា ឲ្យអ្នកក្រាបទូលព្រះចៅក្រុងកម្ពុជាធិបតី ឲ្យព្រះអង្គបើទ្រង់ចង់ព្រះរាជមេត្រី ចូរតាំងព្រះទ័យឲ្យទាំមួនបិតថេរកាលទៅ រាជទូតទាំងពីរក៏ថ្វាយបង្គំលាស្ដេចយួន នាំព្រះអគ្គ (អ៊ឹម) នឹងរាជបណ្ណាការចុះទូកចេញពីស្រុកយួនជាមួយនឹងទូកមន្ត្រីយួន នឹងពលយួន ៥០០ ឡើងរៀនមក លុះដល់ទីប្រទល់ដែនក្រុងកម្ពុជា មន្ត្រីយួនក៏ថ្វាយបង្គំលាទៅស្រុកវិញ ។

ឯចៅហ្វាយស្រុកខ្មែរគ្រប់ទីតាមមាត់ទន្លេបានដឹងថា ព្រះអង្គ (អិម) ស្ដេចមកដល់ហើយ ក៏កេណ្ឌទូកកេណ្ឌមនុស្សឲ្យហែជូនឡើងឡើងមក ។

លុះដល់ថ្ងៃ ១០ កើតខែកត្តិកឆ្នាំជូតនព្វស័ក (ព. ស. ២២៤១) ឧកញ៉ាទាំងពីរនាំព្រះអង្គ (អិម) ដល់កំពង់ហ្លួង ហើយនាំគ្នាឡើងក្រាបបង្គំទូល ព្រះបាទសម្ដេចព្រះបរមបពិត្រ ក្នុងព្រះបរមរាជវាំងឧត្តុង្គឫជ័យ ។ លុះទ្រង់ជ្រាបត្រាស់បង្គាប់ព្រះរាជត្រឡប់ហៅគហោកពារ្យ ទីងឧកញ៉ាមហាមន្ត្រី ឧកញ៉ាមហាទេព ឲ្យអញ្ជើញព្រះពុទ្ធរូបព្រះនារាយណ៍ មកតាំងពិធីពលីការគួរទឹកព្រះពិពទ្ធសច្ចាទុកថ្វាយព្រះអង្គ (អិម) ទទួលព្រះរាជទានទឹកតាមទំនៀម រួចត្រាស់ឲ្យបាតសេនាទាហាន ៦០០ ចុះទៅទទួលហែព្រះអង្គ (អិម) ពីកំពង់ហ្លួងឡើងមកព្រះរាជវាំងឧត្តុង្គឫជ័យ ។

ព្រះបាទសម្ដេចព្រះជ័យជេស្ឋាបរមសុរិន្ទ្រ ស្ដេចចេញទទួលដល់ព្រះរាជពន្លាក្រៅ ព្រះអង្គ (អិម) ក្រាបថ្វាយបង្គំទូលព្រះបាទសុំទោសតាំងពួងដោយសេចក្ដីស្មោះសរ ទ្រង់មានព្រះរាជឧត្តមផ្ទៃ មានបំណងទោសទឹកឃោះ ដែលបានឃើញស្រឡាញ់ទីងនោះដោយបំណែកគេដេៈផ្សេង មានតាំងចិត្តថាទីងនឹងទុកបំរុងឃើញឲ្យដូចជារាជបុត្របង្កើត រួចត្រាស់បង្គាប់ឲ្យព្រះអង្គ (អិម) ទទួលទឹកពិពទ្ធសច្ចាតាមប្រពៃណី ។

# ទ្រង់ផ្សំរាជធីតាជាទេពីព្រះអង្គ (អឹម)

ថ្ងៃក្រោយមក ទ្រង់ត្រាស់បង្គាប់មន្ត្រីមុខក្រសួងឲ្យសង់ព្រះដំណាក់ ក្រោះមានហោណាំងមុខក្រោយ ជញ្ជាំងក្តារធ្វើរបងក្តារជុំវិញ លុះធ្វើរួច ស្រេចមន្ត្រីយកសេចក្តីក្រាបបង្គំទូលសូមទ្រង់ជ្រាប ។

ហើយទ្រង់ប្រឹក្សាទីងនាហ្មឺនសព្វមុខមន្ត្រីទាំងពួងថា អ្នកអង្គ (អឹម) នេះ មានលក្ខណាឫកពាសមសួនល្អ ហើយឯការណាគុណាស់ ដែលព្រះបង្ហុយកាជាបិតាអាជាសត្រូវនឹងយើង ។ មិនពឹងកាយាផង ឥឡូវយើងនឹងផ្ទុំព្រះរាជធីតារបស់យើងឲ្យជាទេពីអ្នកអង្គ (អឹម) គើជាគួរស្មើគ្នាគួរ ។

សេនាបតីមន្ត្រីក្រាបទូលតាមពាក្យបុរាណពោលទុកថា បើសម្លាប់ អាពុកកុំឲ្យតកូន កាប់ដើមកុំឲ្យគល់ចំពាំង ដែលទ្រង់ព្រះមេត្តាព្រះរាជទាន ព្រះរាជធីតាទៅព្រះអង្គ (អឹម) ដូច្នោះ ក្រែងទៅមុខនឹងកើតវល់ឡើង ទៀត តែស្រេចនៅទ្រង់ព្រះចិន្តាតាមគួរពុះ ។

ហើយទ្រង់ព្រះជម្រាសថា បានជាឲ្យទៅយកអ្នកអង្គ (អឹម) ពីស្រុក យួនមកនេះ ព្រោះយល់ឃើញថា បើអ្នកអង្គ (អឹម) នៅតែក្នុងស្រុក យួន ៗ នឹងខ្វះបែរតែធ្វើសង្គ្រាមនឹងគ្នាទៅ ដែលឲ្យទៅនាំយកមកនេះ ប្រយោជន៍នឹងឲ្យបានសេចក្តីសុខដល់បណ្តាស្ត្រស្រុកព្រះនគរ ត្រូវយើង ទំនុកបំរុងឲ្យដល់ចិត្ត ហើយមិនបង្កាយាដញ្ញាបាទនឹងព្រះរាជវង្សានុវង្ស តទៅទៀត ។ នាហ្មឺនសព្វមុខមន្ត្រីក៏យល់ព្រមតាមព្រះរាជតម្រិះ ។

(មានត)

# ប្រយោជន៍របស់ធម្មៈក្នុងពុទ្ធសាសនា

ព្រះគ្រូសុវណ្ណញាណ សូរ-ហាយ ក្រុមជំនុំព្រះត្រៃបិដក

រៀបរៀង

---

ព្រះបរមលោកនាថ ព្រះអង្គមានមហាករុណាចំពោះពួកសត្វ តាំងអំពីកាលព្រះអង្គនៅជាព្រះពោធិសត្វនៅឡើយ ព្រះអង្គមានជីវិតមិនឥតប្រយោជន៍ តែងតែស្វែងរកនូវគុណធំមានសីលគុណជាដើម ដល់តែព្រះអង្គបានត្រាស់ដឹងក្នុងលោក លុះត្រាស់ដឹងហើយទ្រង់តាំងព្រះហឫទ័យធានាក្នុងការសំដែងធម៌ ទូន្មានបញ្ញត្តិវិន័យដោយពុទ្ធអធ្យាស្រ័យដ៏បរិសុទ្ធ ទ្រង់ប្រកបសត្ថុបការកិច្ចទំនុកបម្រុងព្រៀងពួកសត្វ ដើម្បីឲ្យបានគុណសម្បត្តិតាមសមគួរដល់បុគ្គលនិស្ស័យវាសនា ។ កាលព្រះអង្គទើបនឹងបានត្រាស់ឡើងថ្មីៗ ទ្រង់ជញ្ជឹងមើលសត្វលោក ក៏ហាក់ដូចជានឹងរួញរាទាន់ព្រះហឫទ័យក្នុងការសំដែងធម៌ប្រោសសត្វ ដោយទ្រង់យល់ឃើញថា ពួកសត្វទាំងនេះកំពុងឈ្លក់ដោយអារម្មណ៍ជាទីត្រេកអរណាស់តើ! តែក្នុងពេលនោះមានបដិភាណគាថាកើតប្រាស់ដល់ព្រះអង្គថា:

កិច្ឆេន មេ អធិគតំ អលន្ទានិ បកាសិតុំ
រាគទោសបរេតេហិ នាយំ ធម្មោ សុសម្ពុធោ
បដិសោតគាមិំ និបុណំ គម្ភីរំ ទុទ្ទសំ អណុំ
រាគរត្តា ន ទក្ខន្តិ តមោខន្ធេន អាវុដា

សេចក្ដីថា " ឥឡូវនេះគួរនឹងប្រកាសធម៌ដែលតថាគតបានដោយក្រដែរ តែបើសត្វទាំងឡាយ ត្រូវរាគៈទោសៈកំពុងគ្របសង្កត់ទាំងម្ល៉េះ ធ្វើម្ដេចឡើយនឹងអាចឃើញច្បាស់ធម៌បាននោះ; ពួកសត្វដែលមានចិត្តជោកដោយរាគៈ កំពុងរួបរិតដោយគំនរនៃសេចក្ដីងងឹតគឺមោហៈ រមែងមិនឃើញធម៌ដែលជាធម៌ល្អិតម៉ដ្ឋជាដំណើរទៅកាន់ព្រះនិព្វាន ជាធម៌ដ៏ជ្រាលជ្រៅឃើញបានដោយក្រ" ។ លំដាប់ពីនោះមក ទ្រង់ពិនិត្យឃើញផ្កាឈូកដែលដុះក្នុងទឹកមាន ៤ បែបគឺផ្កាទី ១ លូតលាស់ផុតអំពីទឹក លុះអរុណរះឡើងក៏រីកឡើងបានភ្លាម, ផ្កាឈូកទី ២ លូតលាស់ស្មើនឹងទឹក ផ្កាទី ៣ នៅពាក់កណ្ដាលទឹក, ផ្កាទី ៤ ទៀតទើបនឹងពន្លកចេញអំពីដី ។

ឯផ្កាឈូកដែលលូតផុតអំពីទឹកនោះរមែងរីកឡើងបាន ដោយរស្មីព្រះអាទិត្យ, ផ្កាឈូកដែលនៅស្មើនឹងទឹក ថ្ងៃក្រោយគង់រីកឡើងបាន, ផ្កាដែលនៅត្រឹមពាក់កណ្ដាលទឹកមុខជានឹងលូតលាស់រីកឡើងបានក្នុងថ្ងៃខាងក្រោយ, ផ្កាដែលទើបនឹងពន្លកចេញអំពីដីនឹងបានជាអាហារបំណីនៃត្រីនិងអណ្ដើកក៏មាន លូតលាស់រួចឡើងក៏មាន ។ ផ្កាឈូកទាំង ៤ បែបនេះយ៉ាងណាមិញ ពួកសត្វក្នុងលោកក៏យ៉ាងនោះដែរ គឺពួកសត្វទី ១ ហៅថាឧគ្ឃដិតញ្ញូ មានឧបនិស្ស័យពេកសនា ប្រមើនទាន់ត្រាស់ដឹងដោយឆាប់រហ័ស, ទី ២ ហៅថាវិបចិតញ្ញូ មានវាសនាជាលំដាប់បន្ទាប់មក, លុះបានស្ដាប់ធម៌ដោយសេចក្ដីពិស្ដារ ទើបនឹងសម្រេចធម៌ដ៏វិសេសបាន

ទី ៣ ហៅថានេយ្យៈ មានអ្នកសទ្ធាខ្លះមកលុះតែបានស្តាប់ធម៌ សិក្សារៀនសូត្រយកចិត្តទុកដាក់ ប្រតិបត្តិដោយល្អ ទើបសម្រេចធម៌ដ៏វិសេសបាន, ទី ៤ ហៅថាបទបរមៈ ទោះបីបានទទួលសិក្សារៀនសូត្រស្តាប់ ក៏មិនអាចនឹងសម្រេចធម៌វិសេសក្នុងអត្តភាពជាតិនោះបានឡើយ សត្វពួកនេះដែលមិនអាចនឹងទទួលសិក្សារៀនសូត្រស្តាប់សល់នៅច្រើនណាស់ ។ ព្រះសម្មាសម្ពុទ្ធទ្រង់ពិនិត្យឃើញបុគ្គល ៤ ពួក ដែលប្រៀបដូចផ្កាឈូក ៤ បែប ដោយព្រះពុទ្ធញាណហើយព្រះអង្គតាំងព្រះហឫទ័យថា នឹងសំដែងធម៌ប្រោសសត្វតទៅ ។

ធម៌ដែលព្រះសម្ពុទ្ធទ្រង់សំដែងតាំងពីបឋមពោធិកាលរហូតដល់បច្ឆិមពោធិកាល នោះមានឈ្មោះ មានន័យច្រើនយ៉ាងជាអនេក; ធម្មទេសនារបស់ព្រះអង្គ តាមដែលសង្កេតឃើញក្នុងសម្ពី ជួនកាលមានសេចក្តីល្អិតល្អន់ជ្រាលជ្រៅ ជួនកាលកក់ៗ តាមឧបនិស្ស័យរបស់សទ្ធានិងចរិតៈរបស់បរិស័ទអ្នកស្តាប់, បើព្រះអង្គសំដែងធម៌ចំពោះគ្រហស្ថសុទ្ធ ដែលមិនលាយឡំដោយពួកបព្វជិតផងនោះ ច្រើនតែសំដែងចំពោះអំពីអនុបុព្វីកថា ៥ យ៉ាងមានទានកថាជាដើមនាំនូវប្រយោជន៍ ៣ យ៉ាង គឺប្រយោជន៍បច្ចុប្បន្ន ១ បរលោក ១ ព្រះនិព្វាន ១ ។ បើព្រះអង្គសំដែងចំពោះបព្វជិត ច្រើនតែសំដែងអំពីផ្លូវឈាន សមាបត្តិ និងព្រះនិព្វាន ដើម្បីឲ្យសមតាមកិច្ចរបស់អ្នកបួសក្នុងសាសនា ។ មួយទៀតធម្មទេសនា ដែល

ព្រះអង្គសំដែងចំពោះបុគ្គលនោះៗ ច្រើនតែប្រកាសបន្ទូលបង្ហាញធម៌ទាំងពីរចំណែក គឺធម៌ដែលគួរបំពេញឲ្យមានឡើងហៅថា ភាវនាខន្ធ ១ ធម៌ដែលគួរលះចេញហៅថាបហានក្ខន្ធ ១ ។

ធម៌ជាកុសលដែលគួរបំពេញនោះមានច្រើនយ៉ាងមានបុញ្ញកិរិយាវត្ថុ ១០ និងសតិប្បដ្ឋាន ៤ ជាដើមហៅថា ភាវនាខន្ធ ។ ការបំពេញកុសលធម៌តើដើម្បីប្រយោជន៍ដូចម្តេច? នេះជាប្រស្នាដែលត្រូវឆ្លើយដោយពិស្តារ; ប្រយោជន៍ដែលធំបំផុតនៃការបំពេញកុសលធម៌នោះក៏គឺធ្វើកាយវាចាចិត្តឲ្យព្រមព្រៀងដោយកុសលធម៌ ដើម្បីបង្កើនកំឡាំងសេចក្តីល្អ ឲ្យមានគ្រប់គ្រាន់គង់ខ្ជាប់សន្តានឡើង សម្រាប់កំចាត់អកុសលធម៌ដែលជាទំនាស់ប្តូរជាគូសត្រូវដល់កុសលធម៌នោះពោលពេញឲ្យជ្រះស្រឡះ ។ សាមគ្គីសេចក្តីព្រមព្រៀងដោយកុសលជាមេឲ្យមានកំឡាំងខ្លាំងឡើង ដូចកងកាយទាំងមូល កាលបើមានអវយវៈ គឺដៃជើងជាសុខស្រួលមិនវិកលវិការទាំងជនខ្លួនក៏សុខសប្បាយឥតមានជម្ងឺដំណាត់អ្វី គឺថាមានសេចក្តីសុខព្រមព្រៀងគ្រប់អវយវៈទាំងអស់ ជាហេតុឲ្យមានកំឡាំង ទាំងកាយនោះ ទោះទីងចាប់លើករបស់អ្វីមួយឬធ្វើការអ្វីក៏កើតបានងាយ ។ សេចក្តីព្រមព្រៀងរបស់គ្រួសារក្តី ពួកជនផ្សេងៗក្តី សុទ្ធតែជាហេតុឲ្យកើតកំឡាំង ទីងឲ្យមានកិត្តិយសរបស់ពួកទាំងអស់ គ្រួសារឬពួកជនទាំងនោះទីងធ្វើការអ្វីសាចសម្រេចបាន ដូចអ្នកប្រទេស

មួយ ៗ ដែលមានសេចក្ដីព្រមព្រៀងគ្នាជាបច្ច័យ ឲ្យមានកំឡាំងយ៉ាងសំខាន់ក្នុងការរក្សាការពារប្រទេសរបស់គេ សេចក្ដីនេះយ៉ាងណាមិញ ការបោះបង់កាយវាចាចិត្ត ឲ្យមានកុសលសាមគ្គី គឺការព្រមព្រៀងប្រព្រឹត្តល្អត្រូវគ្នាទាំងអស់ មានមេត្តាករុណាស្រឡាញ់រាប់គ្នា ប្រព្រឹត្តសុចរិតស្មោះត្រង់ដល់គ្នានឹងគ្នាមិនឫស្យាគ្នា មិនប្រើអំណាចបៀតបៀនគ្នា ដើម្បីធ្វើកំឡាំងសេចក្ដីល្អឲ្យមានមូលមិត្តមកក្នុងខន្ធ-សន្តានរឿង ទើបអាចនឹងការពារ ចូលដំរះខ្ទរអកុសលជាសឹកសត្រូវដែលនៅក្នុងប្រទេសគឺកាយនោះចេញឲ្យបាត់យ៉ាងនោះដែរ; ដំណើរនេះឈ្មោះថាជាប្រយោជន៍របស់ធម៌ ។

ធម៌ដែលគួរលះបង់ឲ្យស្រឡះចេញនោះមានច្រើនយ៉ាង ៗ ក្នុងគម្ពីរវិសុទ្ធិមគ្គ ត្រង់វិសុទ្ធិនិទ្ទេស មានសេចក្ដីថាពួកបច្ចត្ថិកធម៌គឺជាធម៌សត្រូវដល់កុសលធម៌នោះ បើរាប់តាមមេមាន ១៨ មេគឺ សំយោជនៈ១០, កិលេស ១០, មិច្ឆត្តៈ១០, លោកធម៌ ៨, មច្ឆរិយៈ៥, វិបល្លាសៈ ៣, គន្ថៈ៤, អគតិ ៤, អាសវៈ៤, ឱឃៈ៤ យោគៈ៤, នីវរណៈ៥, បរាមាសៈ១, ឧបាទានៈ៤ អនុស័យ ៧, មលៈ៣; អកុសលកម្មបថ ១០, អកុសលចិត្ត ១២, ទាំងអស់នេះសុទ្ធតែជាអកុសលៈហៅថាបហាតព្វធម៌ គឺកងធម៌ដែលត្រូវលះ ដែលគួរបោះបង់ចេញឬធ្វើឲ្យស្ងប់ម្ងាប់ចាកខន្ធសន្តាន ។

(មានត)

# ធម្មាធិប្បាយ

## សោវចស្សតា

" ភាពជាអ្នកដែលគេស្តីថាងាយឬងាយទូន្មាន "

លោក ស៊ុន-ហ៊ាន រៀបរៀង

---

បុគ្គលជាសប្បុរសក្តី ជនជាអ្នកមានគុណសម្បត្តិព្រមទាំងមានអំណាចកសនាក្តី តែងមានមេត្តាប្រណីចំពោះអ្នកតូចប្រាប់ឲ្យអ្នកតូចស្ទុះស្ទៀនទៅកាន់សេចក្តីចំរើន ហើយទូន្មានប្រៀនប្រដៅអ្នកតូចឲ្យតាំងនៅក្នុងគុណធម៌ផ្សេងៗ ដើម្បីឲ្យប្រព្រឹត្តត្រឹមត្រូវរៀបរយល្អ ។ បើអ្នកតូចបានតាំងនៅក្នុងឱវាទបែបនោះហើយ នឹងមានសួស្តីមង្គលរុងរឿងព្រមទាំងមានកិត្តិគុណប្រាកដច្បាស់ក្នុងលោក ។ អ្នកដែលមិនតាំងនៅក្នុងគុណធម៌បែបនោះទេ, សឹងមានន័យផ្ទុយគ្នា ។

សេចក្តីអធិប្បាយនៃបុគ្គលទាំងពីរប្រភេទនេះ ត្រូវពោលឲ្យជាក់ច្បាស់ដល់លក្ខណៈជាមុន, គឺឯលក្ខណៈជាអ្នកដែលគេស្តីថាក្រ, ទូន្មានប្រៀនប្រដៅក្រ, គឺបានដល់មនុស្សមានមានះ និងទិដ្ឋិរឹងត្អឹងជាអ្នកប្រាជ្ញលាងកលើខ្លួន សង្កត់សង្កិនអ្នកដទៃ, មានសេចក្តីក្រាញប្រឆាំងនៅក្នុងសន្តានចង់សេចក្តីក្រោធទុក ជាអ្នកមានសេចក្តីឈ្នានីស. សូម្បីនឹងពោលកថាឡើងសាកក៏ការក្រត់ បង្ហាញឲ្យឃើញបានថាលាយឲ្យជាប់ទោសពិត, កាលបើមានអ្នកដទៃដាស់តឿនដោយផ្លូវដែលត្រូវ ក៏ផ្ទៃតែប្រកែក

និយាយផ្ចាញ់ប្ដូរស្លាក់ថ្លៃស្លាក់ជំពាក់អ្នកជាសំគៀនឲ្យគាត់និយាយតបវិញមិនរួច, ហើយកុំនិយាយបន្ទុំត្រឡប់ត្រឡិនយកកើនជាតិធ្លាយ ។ មកពោលសំដែងសេចក្ដីគ្រានសេចក្ដីបន្ទូសកំឲ្យប្រាសជ្រាកជ, ទាំងមានអស្សាមប្ចារិយ: ទីឯផលកិច្ចពុតត្បុតច្រើនប្រការ នេះជាលក្ខណ: របស់អ្នកដែលគេស្ដីថាក្រ, ខ្វះនាទៈប្រៀនប្រដៅក្រ ។ កាលបើប្រព្រឹត្តតែហេតុដែលនាំឲ្យកើតសេចក្ដីវិនាសយ៉ាងនេះហើយ មិនបានប្រព្រឹត្តតាមគន្លងរបស់ខ្លួនបុគ្គលហេតុផលមានសេចក្ដីមិនជឿ–ស្ដាប់បំពោះចក្រផ្តួលស្នាការទៀតទេ ម៉ែនមានទោសានុទោសតាមសមគួរដល់កំហុសដែលបានប្រព្រឹត្តលើស ។ ឯភាពនៃបុគ្គលជាអ្នកដែលគេស្ដីថាក្រ, ខ្វះនាទៈប្រៀនប្រដៅក្រ, គង់តែមិនបានទទួលផលគ្រាក់ណាមួយជាប្រាកដ ។ ព្រោះហេតុនោះទើបផ្លូវព្រះពុទ្ធសាសនាប្រដៅមិនឲ្យបុគ្គលជាបុរសស្ដ្រីប្រព្រឹត្តខាន់កាប់សេចក្ដីប្រដៅក្រុកក្នុងនេះឡើយ ដោយហេតុព្រះសម្ពុទ្ធប្រាថ្នាផលមិនដូចគ្នា, បានជាទ្រង់ប្រៀនប្រដៅឲ្យជាអ្នកដែលគេស្ដីថាឆ្ងាយ ខ្វះនាទៈប្រៀនប្រដៅឆ្ងាយវិញ ។

សោវចស្សតានេះ បើគង់បញ្ញាយសេចក្ដីតាមអនុមានសូត្រមជ្ឈិម-និកាយ មជ្ឈិមបណ្ណាសក: ដែលព្រះមោគ្គល្លានត្រាស់ដែងទុកនោះមានសេចក្ដីថា: កាលអ្នកដទៃខ្វះនាទប្រដៅដោយផ្លូវដ៏ល្អ ក៏មានសេចក្ដីអត់ធន់តាំងចិត្តស្ដាប់ដោយគោរព, ប្រាថ្នាតែសេចក្ដីល្អដល់ខ្លួនទាំងអ្នកដទៃ

មិនលើកខ្លួនមិនសង្កត់សង្កិនគេ, មិនជាអ្នកប្រាថ្នាខឹងក្រោធ មិនទាន់បង់សេចក្ដីខឹងក្រោធទុក, មិនប្រណែនឈ្នានីសព្រោះសេចក្ដីក្រោធខឹង, មានវាចាពីរោះស្រួលស្ដាប់, មិនបានជេរគេនិយាយផ្ដេសផ្ដាសស្អាកស្ទះ ត្រឡប់លើកទោសដល់អ្នកដទៃ; បើអ្នកដទៃដាស់តឿនហើយ មិនបានយករឿងក៏ដទៃមកនិយាយបន្លប់ត្រឡប់ត្រឡិនទេ, ទាំងមិនមានសេចក្ដីប្រទូសរ៉ាយ, សេចក្ដីក្រោធខឹងនិងសេចក្ដីតូចចិត្តឡើយ, ជាអ្នកបញ្ចេញពាក្យឲ្យសមនឹងសេចក្ដីប្រព្រឹត្តរបស់ខ្លួន, មិនលុបលាងគុណគេ, មិនលើកខ្លួនផ្ទឹមនឹងគេ, មិនជាអ្នកមានសេចក្ដីកំណាញ់ប្រស្យានឹងអ្នកមានមារយាទរម្យទម់រៀបរយ មិនបះបោរបើនស្មើនក្រៃលែងប្រកែកប្រឆាំងខ្លួន ។ កាលបើប្រកបដោយធម៌ទាំងនេះហើយ ត្រូវមានយោនិសោមនសិការៈ ត្រិះរិះឲ្យឃើញជាក់ច្បាស់ដោយប្រាជ្ញាញាណ ហើយចាំសំគាល់នាំយកទៅប្រតិបត្តិ, សមដូចពុទ្ធភាសិតថា: "សុស្សូសំ លភតេ បញ្ញំ អ្នកស្ដាប់ដោយយកចិត្តទុកដាក់រមែងបានបញ្ញា" ។ ទាំងត្រូវធ្វើសេចក្ដីពិនិត្យខ្លួនឲ្យទាន់ ។ ហើយធ្វើដំណើរបដិបទាឲ្យសមដល់កាលសម័យ សមដូចពុទ្ធភាសិតថា

អត្តានញ្ចេ បិយំ ជញ្ញា រក្ខេយ្យ នំ សុរក្ខិតំ
តិណ្ណមញ្ញតរំ យាមំ បដិជគ្គេយ្យ បណ្ឌិតោ ។

សេចក្ដីថា៖ បណ្ឌិតបើដឹងថាខ្លួនជាទីស្រឡាញ់របស់ខ្លួនឯងហើយ ត្រូវតែរក្សាទុកខ្លួននោះឲ្យល្អ ក្នុងយាម (វ័យ) ទាំងបីណាមួយក្នុងនោះ ៗ

អធិប្បាយថា៖ ក្នុងមួយរាត្រីចែកជាយាមបី ដែលមានឈ្មោះហៅថាយាមបានដូចតទៅនេះ វេលានៃអាយុវ័យដែលចាត់ជាវ័យបី ក៏គួរហៅថាយាមបានដូចគ្នា, ព្រោះហេតុដូច្នោះ ទើបសម្ដេចព្រះវិជិតមារទ្រង់សំដែងធម្មគាថានេះ ហៅវ័យថាជាយាម ដើម្បីឲ្យមានសេចក្ដីស្របគ្នា លុះបុគ្គលជាអ្នកស្ដីថាងាយ ខ្លួនប្រាថ្នាយបានដឹងច្បាស់ថាខ្លួនខុស គួរប្រកបកិច្ចជាប្រយោជន៍សម្រាប់ខ្លួនឲ្យសម្រេចក្នុងយាមដើម (បឋមវ័យ) បើធ្វើមិនទាន់គួរប្រឹងប្រែងឲ្យសម្រេចក្នុងយាមកណ្ដាល (មជ្ឈិមវ័យ) បើថាទៅដល់ខ្លួនក្នុងយាមទីបំផុត ក៏គួរប្រញាប់ប្រញាល់ធ្វើឲ្យសម្រេចទាន់ពេលវេលា កុំបង្អែបង្អង់ថាចាំធ្វើក្នុងថ្ងៃស្អែកឬថ្ងៃក្រោយឡើយ កាលបើការងារបណ្ដោះបណ្ដែដូច្នេះនឹងត្រឡប់ក្លាយទៅជាសេចក្ដីប្រមាទ ដឹកនាំចិត្តឲ្យទ្រេតទ្រោតទីសចាសខុសផ្លូវ ហេតុនេះទើបព្រះដ៏មានព្រះភាគទ្រង់ត្រាស់ថា៖

"ទន្ធំ ហិ ករោតោ បុញ្ញំ បាបស្មឹ រមតិ មនោ"

កាលធ្វើសេចក្ដីល្អយឺតយូរពេកទៅ ចិត្តក៏រមែងត្រេកអរក្នុងសេចក្ដីអាក្រក់ ៗ គួរនឹកដល់ព្រះបរមពុទ្ធោវាទមួយទៀតដែលព្រះដ៏មានព្រះភាគត្រាស់ថា៖

"អជ្ជេវ កិច្ចមាតប្បំ កោ ជញ្ញា មរណំ សុវេ"

ត្រូវតែប្រឹងធ្វើកិច្ចក្នុងថ្ងៃនេះឲ្យហើយកុំខាន, ព្រោះអ្នកណានឹងអាចដឹងបានថាសេចក្ដីស្លាប់នឹងមានមកក្នុងថ្ងៃស្អែក ? ។

អធិប្បាយថា: គួរតែធ្វើសេចក្ដីព្យាយាមឲ្យសម្រេចកិច្ចដែលជាប្រ-យោជន៍សម្រាប់ខ្លួនក្នុងថ្ងៃនេះ កុំពង់អល់ឯកបណ្ដោះបណ្ដោះទៅថ្ងៃស្អែកឡើយ, ព្រោះថាគ្មានអ្នកណាមួយអាចដឹងបានថាអាត្មាអញនឹងស្លាប់ក្នុងថ្ងៃនេះឬថ្ងៃស្អែកទេ ។ ការប្រញាប់ខ្វល់ខ្វាយប្រគបកិច្ចដែលជាប្រយោជន៍ឲ្យទាន់កាលសម័យរបស់វ័យចាត់ជាផលរបស់សោវចស្សតា ។ ក្នុងច្បាប់ព្រះពុទ្ធសាសនា ទំនាយមកចំណានយកសោវចស្សតាធម៌នេះថាជាសេចក្ដីល្អរបស់អ្នកប្រព្រឹត្តទាំងផ្លូវលោកនិងផ្លូវធម៌ទៅ ។

អ្នកមានប្រាជ្ញាគួរឃើញគុណរបស់សោវចស្សតា ដែលឲ្យផលអស្ចារ្យ ដូចទីឃាវុកុមារដែលបានជាស្ដេចធំលើផែនដីទាំងពីរ គឺដែនកាសីនិងកោសល ក៏ព្រោះផលនៃគុណធម៌នេះឯងដូចសំដែងតទៅនេះ .

កាលព្រះបាទព្រហ្មទត្តនគរពារាណសី ដែនកាសីលើកទ័ពទៅវាយដែនកោសលបាន, ព្រះបាទទីឃីតិ នគរសាវត្ថីដែនកោសល ទ្រង់នាំព្រះមហេសីមានគភ៌ទៅគង់ក្នុងវិបផុតដែន, ថ្ងៃក្រោយទ្រង់ប្រសូតកូនប្រុសទ្រង់ព្រះនាមថា "ទីឃាវុ" ។ លុះទីឃាវុកុមារមានវ័យចំរើនល្មមដឹងក្ដី ព្រះបាទព្រហ្មទត្តចាប់ព្រះបាទទីឃីតិបានឲ្យនាំទៅ

សម្លាប់, គ្រានោះទីឃាវុមកចាំ ព្រះបាទទីឃីតិទ្រង់ប្រដៅថា "នែទីឃាវុ អ្នកកុំឃើញកាលវែងពេកខ្លីពេក, ធម្មតាពៀរពុំដែលរម្ងាប់ដោយពៀរទេ តែងរម្ងាប់ដោយការពុំចងពៀរ" ទ្រង់ផ្តាំស្រេចគេក៏សម្លាប់ទៅ ។

បំណាមកខាងក្រោយ ទីឃាវុបានចូលថ្វាយខ្លួនជាខ្ញុំពជការយានស៊ូទ្ធទីនព្រះបាទព្រហ្មទត្ត, ថ្ងៃមួយព្រះបាទព្រហ្មទត្តទ្រង់ស្តេចទៅប្រពាត់ព្រៃ ទីឃាវុជានាយសារថីបររាជរថ ។ ទីឃាវុបានឱកាសក៏បររាជរថទៅមុនពួកពល ។ វេលានោះព្រះបាទព្រហ្មទត្តទ្រង់ផ្ទំកើយភ្លៅទីឃាវុដោយនឿយព្រះកាយពល, កំពុងតែផ្ទំស្កល់ ទីឃាវុលើកព្រះខ័នឡើងបំរុងនឹងសម្លាប់ តែនឹកគិតដល់បណ្តាំព្រះបិតាក៏ឈប់ទៅវិញ គ្រាន់តែស្រែកសម្តាប់ឲ្យព្រះបាទព្រហ្មទត្តជ្រាបថា ជារាជបុត្រព្រះបាទទីឃីតិប៉ុណ្ណោះ ។ គ្រានោះក្សត្រទាំងពីរក៏ប្រទានអភ័យទៅវិញទៅមក ហើយទ្រង់ស្តេចត្រឡប់ទៅព្រះនគរវិញ, ព្រះបាទព្រហ្មទត្តក៏ប្រទានដែនទាំងពីរគឺដែនកោសលនឹងដែនកាសីឲ្យទីឃាវុ ។ ព្រមទាំងប្រទានព្រះរាជធីតាជាព្រះរាជមហេសីផង ។

ព្រះបាទទីឃាវុបានគ្រងរាជ្យជាធំ លើដែនទាំងពីរក៏ដោយសារជាបុគ្គលឆ្លាយប្រដៅ គឺស្តាប់ព្រះរាជឱវាទរបស់ព្រះបាទទីឃីតិជាព្រះបិតាដូចពោលមកខាងដើមហើយយកទៅធ្វើតាមត្រូវតាមលក្ខណៈសោវត្ថិស្យគានេះឯង ។

ហេតុនេះបានជាព្រះបរមសាស្តាទ្រង់ត្រាស់គុណធម៌នេះថាជាធានា-ឋការណធម៌ ក្នុងនាថករណធម្មសូត្រ ទ្រង់ត្រាស់ថាជាឧត្តមមង្គល ក្នុងមង្គលសូត្រ; អ្នកដែលតាំងនៅក្នុងគុណសម្បត្តិដូច្នេះហើយ ព្រះអង្គក៏ទ្រង់ត្រាស់សរសើរទុក ដើម្បីឲ្យអនុបរិស័ទនឹងបានកាន់តាមយកជាគម្រាប់ ៗ ដូចយ៉ាងព្រះរាធត្ថេរលោកជាអ្នកដែលគេស្តីថាងាយ, ទូន្មានប្រៀនប្រដៅងាយ, កាលបើឧបជ្ឈាយ៍ឬអាចារ្យស្តីថា ពោលប្រៀនប្រដៅក៏ធ្វើតាមឥតប្រកែក ដោយលោកតាំងនៅក្នុងលក្ខណៈនៃគុណធម៌នេះ តាំងជាអ្នកមិនមានសេចក្តីប្រមាទ ហើយព្យាយាមខ្នះខ្នែងប្រតិបត្តិដរាបដល់បានសម្រេចព្រះអរហត្តជាបរិយោសាន ៗ ហេតុនោះ ទើបព្រះអង្គទ្រង់ប្រទានទុកដល់បរិស័ទ ដើម្បីធ្វើខ្លួនឲ្យបានទៅជាអ្នកដែលគេស្តីថាងាយ, ទូន្មានប្រៀនប្រដៅងាយដូចយ៉ាងព្រះរាធៈដែរ ៗ ភាពជាអ្នកដែលគេស្តីថាងាយ, ទូន្មានប្រៀនប្រដៅងាយ ជាហេតុនៃសេចក្តីល្អគ្រប់បែប, សាធុជនដែលដឹងថាខ្លួនឯងជាទីស្រឡាញ់របស់ខ្លួននឹងប្រាថ្នាសេចក្តីល្អដល់ខ្លួន គួរប្រព្រឹត្តកាន់តាមលក្ខណៈ សោ-វចស្សតានឹងបានទៅជាពន្លឺបំភ្លឺខ្លួនឯង រហូតដល់ពួកគណៈនឹងប្រទេសជាតិ ៗ ចប់